មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ ហោ វ៉ន ភេទស្រី អាយុ៥៩ឆ្នាំ

# មុខងារសម័យខ្មែរក្រហមៈ "នារីស្រែអំបិល"

## ស្រុកកំណើតនៅភូមិពងទឹក ឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវ

## រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ម៉ម សុវណ្ណ

## ០១:០៨:០៨

## ៣៦ទំព័រ

សុវណ្ណៈ	មីងជីបូងខ្ញុំសូមជំរាបសួរ ។

វ៉នៈ	ចាស ។

សុវណ្ណៈ	ខ្ញុំសូមណែនាំខ្លួនឲ្យស្គាល់ខ្ញុំឈ្មោះ សុវណ្ណ មីង ។

វ៉នៈ	ចាស ។

សុវណ្ណៈ	ខ្ញុំជាបុគ្គលិកនៅក្នុងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃនេះថ្ងៃទី២២ខែ១២ឆ្នាំ២០១៣ ដើម្បីជួបមីងចង់ដឹងជីវិតរបស់មីងដែលធ្លាប់ឆ្លងកាត់មកតាំងពីក្មេងរហូតមកដល់បច្ចុប្បន្ននេះ ថាតើវាមានរឿងយ៉ាងណាខ្លះ?

វ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងជីបូងខ្ញុំចង់ដឹងឈ្មោះ តើមានឈ្មោះអីគេ?

វ៉នៈ	ខ្ញុំឈ្មោះ ហោ វ៉ន ។

សុវណ្ណៈ	សព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

វ៉នៈ	ខ្ញុំអាយុ៥៩ ។

សុវណ្ណៈ	មីងកើតឆ្នាំណាមីងមានចាំទេ?

វ៉នៈ	ខ្ញុំកើតឆ្នាំ១៩៥៤ ។

សុវណ្ណៈ	សព្វថ្ងៃមីងធ្វើអីគេ?

វ៉នៈ	ខ្ញុំធ្វើស្រែ ។

សុវណ្ណៈ	ក្រៅពីធ្វើស្រែមីងមានធ្វើអីផ្សេងទៀតទេ?

វ៉នៈ	ខ្ញុំដាំដំណាំរួមផ្សំដូចជាអំពៅដូចជាចេកអីហ្នឹង ។

សុវណ្ណៈ	ចឹងគ្រួសារមីងគាត់ឈ្មោះអីដែរ?

វ៉នៈ	គាត់ឈ្មោះ ឆែម ហួន ។

សុវណ្ណៈ គាត់សព្វថ្ងៃធ្វើអីគេ?

វ៉ានៈ គាត់សព្វថ្ងៃធ្វើជាមេភូមិ ។

សុវណ្ណៈ ភូមិនេះគេហៅភូមិអីគេ?

វ៉ានៈ ភូមិអូរស្វាយ ។

សុវណ្ណៈ អូរស្វាយចាស់ឬអូរស្វាយថ្មី?

វ៉ានៈ អូរស្វាយចាស់ ភូមិអូរស្វាយ ឃុំអូរស្វាយ ។

សុវណ្ណៈ ចឹងភូមិអូរស្វាយឬអូរស្វាយចាស់?

វ៉ានៈ ហៅអូរស្វាយចឹងតែម្តង ។

សុវណ្ណៈ ចឹងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ?

វ៉ានៈ ចាស ។

សុវណ្ណៈ មីងមានកូនប៉ុន្មាននាក់?

វ៉ានៈ ខ្ញុំមានកូន៥នាក់ ។

សុវណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

វ៉ានៈ ប្រុសមួយស្រីបួន ។

សុវណ្ណៈ មានគ្រួសារអស់ហើយនៅកូនៗ?

វ៉ានៈ កូនខ្ញុំនៅសល់លីវមួយ ។

សុវណ្ណៈ ហើយលីវហ្នឹងនៅរៀនទេ?

វ៉ានៈ នៅរៀនថ្នាក់ទី៧ ។

សុវណ្ណៈ ចឹងរៀនហ្នឹងមីងចង់ឲ្យកូនធ្វើអីទៅថ្ងៃក្រោយ?

វ៉ានៈ ចិត្តកូនខ្ញុំគេចង់ធ្វើប៉េអឹម ។

សុវណ្ណៈ កូនមីងនៅរៀនស្រីឬប្រុស?

វ៉ានៈ កូនស្រី ។

សុវណ្ណៈ ចឹងកូនស្រីចង់ធ្វើប៉េអឹម?

វ៉ានៈ ចាស! សើច... ។

សុវណ្ណៈ យ៉ាងម៉េចបានចង់ធ្វើប៉េអឹមចឹង?

វ៉ានៈ មិនដឹងជាយ៉ាងម៉េចគេ ។

សុវណ្ណៈ ចឹងសម្រាប់មីងផ្ទាល់ចង់ឲ្យកូនធ្វើអីគេទៅថ្ងៃក្រោយ ការគិតរបស់មីង?

វ៉ានៈ ខ្ញុំថាស្រេចចិត្តកូន ឲ្យតែគេខំរៀនបានចេះ ។

សុវណ្ណៈ តែសម្រាប់មីងផ្ទាល់ចង់ឲ្យកូនធ្វើអី?

វ៉នៈ បើតាមចិត្តខ្ញុំចង់ឲ្យរៀនពេទ្យនោះ ។

សុវណ្ណៈ មូលហេតុអីចង់ឲ្យរៀនពេទ្យ?

វ៉នៈ វាស្រួលឈឺស្អាត់អីទៅបានកូនចេះ ។

សុវណ្ណៈ ចឹងកាលមីងនៅក្មេងមានបានគិតទេ ថាថ្ងៃក្រោយធំឡើងចង់ធ្វើនេះចង់ធ្វើនោះអីដែលទេ?

វ៉នៈ គោលបំណងខ្ញុំចង់ធ្វើពេទ្យតាំងពីក្មេង ។

សុវណ្ណៈ ដោយសារអីគេមីងចង់ធ្វើពេទ្យ?

វ៉នៈ ខ្ញុំចង់ចេះចឹងតែម្តង តែដល់មិនបានសម្រេច ។

សុវណ្ណៈ មីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

វ៉នៈ បងប្អូនបង្កើតមានបួននាក់ ។

សុវណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មានមីង?

វ៉នៈ សុទ្ធតែស្រី ។

សុវណ្ណៈ ស្រីទាំងអស់?

វ៉នៈ ចាស ។

សុវណ្ណៈ មីងកូនទីប៉ុន្មាន?

វ៉នៈ កូនទី៣ ។

សុវណ្ណៈ បងបន្ទស់អាយុប៉ុន្មានមីង?

វ៉នៈ បងបន្ទស់អាយុប៉ុន្មានទេ ប្រហែល៦០ជាងហើយ ។

សុវណ្ណៈ មីងមានស្រុកកំណើតនៅណា?

វ៉នៈ ខ្ញុំនៅឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវ ។

សុវណ្ណៈ ភូមិអីគេមីង?

វ៉នៈ ភូមិពងទឹក ។

សុវណ្ណៈ ចឹងឪពុកមីងឈ្មោះអីគេ?

វ៉នៈ ឈ្មោះ ហោ ណង់ ម្តាយស្លាប់ហើយ ។

សុវណ្ណៈ ចឹងម្តាយឈ្មោះអីគេ?

វ៉នៈ ម្តាយឈ្មោះ អោម ផន ។

សុវណ្ណៈ ចឹងឪពុកស្លាប់ឆ្នាំណាមីង?

វ៉នៈ គាត់ទើបស្លាប់បានពីរហើយ ។

សុវណ្ណៈ	កាលគាត់ស្លាប់អាយុប៉ុន្មាន?
វ៉ន:	គាត់អាយុ៨៩ ។
សុវណ្ណៈ	ចុះពេលម្ដាយ?
វ៉ន:	ម្ដាយស្លាប់តាំងពីខ្ញុំនៅតូច ។
សុវណ្ណៈ	ស្លាប់ពេលណាកាលនៅតូចហ្នឹង?
វ៉ន:	ខ្ញុំទើបអាយុបានតែ៩ឆ្នាំ ។
សុវណ្ណៈ	ចឹងកាលពីមីងនៅក្មេងមីងមានចូលរៀនសូត្រទេ?
វ៉ន:	បានរៀន ។
សុវណ្ណៈ	មីងរៀនបានត្រឹមថ្នាក់ទីប៉ុន្មាន?
វ៉ន:	រៀនបានត្រឹមថ្នាក់ទី៧ «ចាស់» ។
សុវណ្ណៈ	ចឹងថ្នាក់ទី៧ចាស់ហ្នឹង បើយើងគិតពេលបច្ចុប្បន្នប្រហែលជាថ្នាក់ទីប៉ុន្មានមីង?
វ៉ន:	មិនដឹងជាថ្នាក់ទីប៉ុន្មានទេ ឥឡូវគេរាប់ផ្សេង ។
សុវណ្ណៈ	កាលរៀន រៀននៅសាលាណា?
វ៉ន:	រៀននៅសាលាបឋមសិក្សាអង្គរមន្ត្រី នៅជិតផ្ទះ ។
សុវណ្ណៈ	អង្គរមន្ត្រី?
វ៉ន:	ចាស ។
សុវណ្ណៈ	ឥឡូវមីងមានដឹងថាគេដាក់ឈ្មោះអីវិញទេ?
វ៉ន:	គេដាក់ចឹងឯង ។
សុវណ្ណៈ	ចឹងកាលមីងនៅក្មេងជីវភាពមីងរស់នៅជាមួយឪពុកម្ដាយយ៉ាងម៉េចដែរ?
វ៉ន:	ខ្ញុំម៉ាល្មមម៉ាសមរម្យ ។
សុវណ្ណៈ	កាលហ្នឹងឪពុកម្ដាយធ្វើអីគេ?
វ៉ន:	ធ្វើស្រែទេ ។
សុវណ្ណៈ	ចឹងធ្វើស្រែចម្ការទេ?
វ៉ន:	ចាស ។
សុវណ្ណៈ	ចឹងការហូបចុកអីមានខ្វះខាតទេ?
វ៉ន:	ជីវភាពត្រឹមហូបចុកបានគ្រប់គ្រាន់ហ្នឹងឯង ។
សុវណ្ណៈ	ចឹងមីងឈប់រៀនត្រឹមថ្នាក់ទី៧ដោយសារមានមូលហេតុអីគេ?

រ៉នៈ មួយសារនោះឪពុកខ្ញុំថាឲ្យរៀនតែត្រឹមហ្នឹងបានហើយ ព្រោះខ្ញុំមានម្ដាយចុងទៀតគាត់អត់ចង់ឲ្យរៀន ។

សុវណ្ណៈ ចឹងឪពុកមីងរៀបការគ្រួសារក្រោយនៅពេលណាមីង?

រ៉នៈ ខ្ញុំអាយុ៩ឆ្នាំ១០ឆ្នាំហើយគាត់ការ ។

សុវណ្ណៈ ចឹងឪពុកថារៀនត្រឹមហ្នឹងហើយមិនបាច់ទៅរៀនអីទៀតទេ?

រ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលមីងឈប់រៀន មីងមកធ្វើអីគេ?

រ៉នៈ ខ្ញុំឈប់រៀនខ្ញុំនៅផ្ទះ ធ្វើស្រែចម្ការ ។

សុវណ្ណៈ មកជួយធ្វើស្រែចម្ការជាមួយឪពុកម្ដាយទៅ?

រ៉នៈ ចាស ។

សុវណ្ណៈ ចឹងសម្រាប់មីងផ្ទាល់ មីងគិតថាការអប់រំសំខាន់ទេមីង?

រ៉នៈ សំខាន់ ។

សុវណ្ណៈ ពីមុនមកដល់ពេលបច្ចុប្បន្ននេះ មីងគិតថាការអប់រំសំខាន់ឬមិនសំខាន់មីង?

រ៉នៈ សំខាន់ ។

សុវណ្ណៈ សំខាន់យ៉ាងម៉េចទៅមីង?

រ៉នៈ សំខាន់សម្រាប់ជីវិតយើងទៅមុខទៀត យើងចេះទៅយើងរកការងារអីឆាប់បានធ្វើយើងស្រួលកុំឲ្យពិបាកដូចម៉ែឪ ធ្វើស្រែចម្ការយ៉ាប់ណាស់ ។

សុវណ្ណៈ ចឹងមីងកាលហ្នឹងមុនរដ្ឋប្រហារលន់ នល់ ទៀត នៅឆ្នាំ១៩៧០តើពេលហ្នឹងសភាពការណ៍នៅក្នុងភូមិយ៉ាងម៉េចដែលមីង នៅក្នុងភូមិរស់នៅ?

រ៉នៈ អត់មានអីទេធម្មតា ខ្ញុំនៅក្មេងៗដែរ ពេលរដ្ឋប្រហារក៏នៅតែក្នុងភូមិហ្នឹងជាមួយម៉ែឪរហូតដល់ពេលឆ្នាំ៧២-៧៣អីហ្នឹង បានជួបការលំបាក ដូចថាមានទាហានចុះមកឡើងមកអីចឹងវាបាញ់ យើងរត់លូនចឹងទៅវាពិបាក ។

សុវណ្ណៈ ទាហានខាងណាមកបាញ់?

រ៉នៈ កាលនោះគេហៅថា ចេនឡាទី២ អីយ៉ាងម៉េចនោះ ទាហាន លន់ នល់ ។

សុវណ្ណៈ ចឹងទាហាន លន់ នល់ មកបាញ់?

រ៉នៈ ចាស ។

សុវណ្ណៈ មកបាញ់ខាងណា?

រ៉នៈ មកបាញ់ពួកខ្មែរក្រហមអីហ្នឹង នៅព្រៃអីមកតាមភូមិចឹង គេឡើងមកយើងក៏ពិបាកនិងរត់រួច មានអាកន្ទុំរុយហោះចុះឡើងចឹងដេញរត់ ខ្ញុំរត់ចឹងឯង ។

សុវណ្ណៈ ចឹងមីងកាលហ្នឹងមានចូលបដិវត្តជាមួយគេហើយឬនៅ?

រ៉នៈ ខ្ញុំដល់ពេលយូរទៅឆ្នាំ៧៥ គេឲ្យចូល យើងនៅផ្ទះមិនបានទេ យើងត្រូវតែចូល នាំចូលធ្វើការងាររចឹង ខ្ញុំទៅធ្វើនៅស្រែអំបិលខ្ញុំ ។

សុវណ្ណៈ ចឹងកាលទាហាន លន់ នល់ បាញ់ជាមួយខ្មែរក្រហមហ្នឹង កាលហ្នឹងមីងរត់ទៅណា?

រ៉នៈ រត់កាលហ្នឹងនៅជិតៗផ្ទះដែលហ្នឹង ល្ងាចចឹងមកវិញហើយ រត់ទៅជិតភ្នំហ្នឹង ។

សុវណ្ណៈ រត់នៅជិតភ្នំណា?

រ៉នៈ ភ្នំដីវីរមាល ។

សុវណ្ណៈ ចឹងនៅពេលដែលមានបាញ់គ្នាម្ដងៗ យើងនាំគ្នារត់ទៅខាងភ្នំដីវីរមាលទៅ?

រ៉នៈ ចាស! យើងរត់ទៅជិតភ្នំវាមិនហ៊ានមកទៀតទេ ។

សុវណ្ណៈ ចឹងពេលគេបាញ់គ្នាចប់យើងត្រឡប់មកផ្ទះមក?

រ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលហ្នឹងខស្សាហ៍បាញ់គ្នាទេ?

រ៉នៈ ចាស! ខស្សាហ៍បាញ់ដែរ បួនទៅប្រាំថ្ងៃមួយអាទិត្យចឹងវាឡើងមកបាញ់គ្នាម្ដង ដល់ពុស្សូរ្យនាំគ្នារៀបរត់ទៀតហើយ្យ ។

សុវណ្ណៈ ចឹងកាលហ្នឹងនៅក្នុងភូមិមីង ខាងលន់ នល់ គ្រប់គ្រងឬខាងខ្មែរក្រហមគ្រប់គ្រង?

រ៉នៈ កាលហ្នឹងមានឈ្លប ដូចជាឈ្លបខ្មែរក្រហមហើយ មានកងទ័ពខ្មែរក្រហម ។

សុវណ្ណៈ ខ្ញុំចង់និយាយថា ពេលកើតមានរដ្ឋប្រហារនៅឆ្នាំ១៩៧០ ចឹងភូមិមីងនៅក្រោមការគ្រប់គ្រងរបស់ លន់ នល់ ឬនៅក្រោមការគ្រប់គ្រងរបស់ លន់ នល់ ពេលថ្មីៗទម្លាក់សម្ដេចហ្នឹង?

រ៉នៈ កាលហ្នឹងនៅ លន់ នល់ ដែលទេ ។

សុវណ្ណៈ ចឹងនៅលន់ នល់ ទេ?

រ៉នៈ ចាស ។

សុវណ្ណៈ ចឹងក្រោយមកបានមានខ្មែរក្រហមចូលមកភូមិអី?

រ៉នៈ នៅជាមួយ លន់ នល់ តាមខេត្ត តាមបន្ទាយនៅតាមផ្សារហ្នឹង សុទ្ធតែទាហាន លន់ នល់ ដោយឡែកខាងខ្ញុំជនបទចឹងទៅវាមានឈ្លបខ្មែរក្រហមចុះឡើងចឹងទៅ ដល់ពេលនេះគេឡើងមកហើយ ។

សុវណ្ណៈ ចឹងឈ្លបខាងខ្មែរក្រហមចេញចូលចុះឡើងតាំងពីឆ្នាំណាមក?

រ៉ន: តាំងពីឆ្នាំ៧០ - ៧១ - ៧២ហ្នឹងមានរហូត ។

សុវណ្ណៈ ចឹងខ្មែរក្រហមចាប់ចូលភូមិបណ្តើរតាំងពីឆ្នាំ៧០មក ៧០ចាប់ផ្តើមមកបណ្តើរហើយ?

រ៉ន: ឆ្នាំ៧២ ។

សុវណ្ណៈ ចឹងកាលហ្នឹងគេមានឃោសនាប្រជាជនឲ្យចូលរួមបដិវត្តជាមួយគេទេ?

រ៉ន: មាន ។

សុវណ្ណៈ ចឹងភូមិមីងមានពីណាចូលរួមខ្លះទេ?

រ៉ន: ខ្លះគេចូលរួមដែលហ្នឹង ខ្លះគេចាស់ជាងខ្ញុំអី គេទៅចូលតស៊ូអីចឹងទៅ ឥឡូវស្លាប់អស់ហើយហ្នឹង ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងមានមូលហេតុអីបានជាមិនចូលរួមជាមួយគេចឹង?

រ៉ន: ខ្ញុំនៅក្មេងហើយម្យ៉ាងនឹកឃើញខ្លួនឯងស្រី មិនចង់បែកទៅឆ្ងាយ ។

សុវណ្ណៈ ហើយមីងឃើញគេចូលនៅក្នុងភូមិមីង ភាគច្រើនគេចូលឬមិនចូលមីង?

រ៉ន: ភាគច្រើន យើងត្រូវតែចូលហើយ ចឹងទៅប្រុសៗគេច្រើនចូល ស្រីៗមិនហ៊ានទៅឆ្ងាយចឹងទៅ ។

សុវណ្ណៈ ចឹងមីងគិតថា គេចូលជាមួយខ្មែរក្រហមហ្នឹងគេចូលដើម្បីអីគេ?

រ៉ន: គេចូលថាដើម្បីរំដោះខ្លួនរំដោះវណ្ណៈ ។

សុវណ្ណៈ ចឹងដើម្បីរំដោះខ្លួនរំដោះវណ្ណៈ?

រ៉ន: ចាស! ព្រោះគេធ្វើបដិវត្ត ។

សុវណ្ណៈ ចឹងគេចូលរួមចលនាជាមួយខ្មែរក្រហមទៅ?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងបន្ទាប់មកនៅក្នុងឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមគ្រប់គ្រងប្រទេសបាន គេឲ្យមីងធ្វើអីគេកាលហ្នឹង?

រ៉ន: ខ្ញុំទៅធ្វើស្រែអំបិល ។

សុវណ្ណៈ ចឹងមីងគេឲ្យទៅធ្វើនៅស្រែអំបិល?

រ៉ន: ចាស! ចេញពីផ្ទះទៅស្រែអំបិល ។

សុវណ្ណៈ ចឹងពេលខ្មែរក្រហមចូលមកភ្លាមៗហ្នឹងគេមានជម្លៀសគ្រួសារមីង មានជម្លៀសបងប្អូនឲ្យទៅណាទៅណីទេ ឬនៅតែក្នុងភូមិទេ?

រ៉ន: ខ្ញុំនៅតែក្នុងភូមិ ។

សុវណ្ណៈ ចឹងនៅក្នុងភូមិទេ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងដោយខ្មែរក្រហមគេជ្រើសរើសមីងឲ្យទៅធ្វើការនៅស្រែអំបិល?

វ៉ន: ចាស ។

សុវណ្ណៈ ចូលទៅស្រែអំបិលចូលទៅធ្វើការនៅខាងណា នៅខេត្តណាស្រែអំបិលហ្នឹង?

វ៉ន: នៅខេត្តកំពត ។

សុវណ្ណៈ ចឹងមីងមានដឹងថា យើងធ្វើនៅតំបន់ណាទេមីង នៅភូមិអីគេកាលហ្នឹង?

វ៉ន: គេហៅកំពង់ណុង ។

សុវណ្ណៈ កំពង់ណុង?

វ៉ន: ចាស! នៅចន្លោះសេះស ខេត្តកំពតអាហ្នឹងនៅចន្លោះកណ្តាល ។

សុវណ្ណៈ កាលហ្នឹងស្រុកអីគេ កាលហ្នឹងមីង?

វ៉ន: ដឹងថាស្រុកអីទេ ។

សុវណ្ណៈ កាលហ្នឹងឆ្នាំ៧៥ភ្លាម គេបញ្ជូនទៅភ្លាមតែម្តង?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងនៅក្នុងភូមិមីង មានប៉ុន្មាននាក់គេរើសទៅធ្វើការនៅស្រែអំបិលហ្នឹង?

វ៉ន: ខ្ញុំទៅតែឯង ។

សុវណ្ណៈ មីងទៅតែឯងទេ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងក្មេងៗផ្សេងៗទៀតនោះ?

វ៉ន: ក្មេងៗផ្សេងៗទៀត ច្រើននៅតាមស្រុក តាមឃុំគេផ្សេង ។

សុវណ្ណៈ មានមូលហេតុអីបានជាគេរើសមីងមកតែឯងចឹង?

វ៉ន: ខ្ញុំគេឃាត់មិនឲ្យទៅដែរ តែខ្ញុំមិនចង់នៅក្នុងស្រុក វារត់លូននេះទេ ខ្ញុំខ្ជិលខ្ញុំចង់ទៅស្រែអំបិល ។

សុវណ្ណៈ ចឹងមីងចង់ទៅដែរ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងពីណាអ្នកនាំទៅ?

វ៉ន: កាលហ្នឹងមាននារីឃុំអីហ្នឹង គេអ្នកដឹកនាំយើង ។

សុវណ្ណៈ ចឹងតំបន់នេះ នៅពេលខ្មែរក្រហមគ្រប់គ្រងបានគេហៅតំបន់អីមីង នៅតាកែវហ្នឹង?

វ៉នៈ តំបន់១៣ ។

សុវណ្ណៈ ចឹងមូលហេតុអីបានជាមីងដឹងថាតំបន់១៣?

វ៉នៈ ចុះគេប្រើពាក្យចឹងរហូត តំបន់៣៣តំបន់១៣តំបន១៥ចឹងទៅតំបន៣៥តំបន់កំពត គេហៅតំបន់៣៥ ខាងខ្ញុំ១៣ ខាងកំពង់ស្ពឺ៣៣ចឹងទៅ ចេះតែប្រើពាក្យហ្នឹងរហូតទៅ ។

សុវណ្ណៈ ចឹងមីងដឹងតាមរបៀបយ៉ាងម៉េច មីងដឹងតាមគេហៅឬដឹងដោយខ្លួនឯង?

វ៉នៈ ឮតាមគេហៅ គេប្រើពាក្យ ។

សុវណ្ណៈ ចឹងមីងធ្វើការនៅខាងស្រែអំបិលគេហៅតំបន់ប៉ុន្មាន?

វ៉នៈ គេហៅតំបន់៣៥ ។

សុវណ្ណៈ ចុះគណៈតំបន់៣៥ពីណាគេ មីងមានស្គាល់ទេ?

វ៉នៈ អត់ស្គាល់ទេ ព្រោះខាងរដ្ឋអំណាច ។

សុវណ្ណៈ ចុះគណៈស្រុក?

វ៉នៈ គណៈស្រុកក៏អត់ស្គាល់ ខ្ញុំអត់ដែលដឹងទេ ។

សុវណ្ណៈ ចឹងកន្លែងមីងធ្វើការហ្នឹងពីណាជាអ្នកគ្រប់គ្រង?

វ៉នៈ វរសេនាតូចឈ្មោះ បងរីម គាត់ស្រី ខ្ញុំស្គាល់ត្រឹមហ្នឹងឯង ។

សុវណ្ណៈ បងរីម ហ្នឹងគាត់មកពីខាងណាវិញ?

វ៉នៈ បងរីម គាត់ទៅពីកំពង់ឆ្នាំង ។

សុវណ្ណៈ ចឹងម៉េចបានដឹងថាគាត់នៅកំពង់ឆ្នាំង?

វ៉នៈ ចឹងចូលចឹងទៅ យើងដឹងប្រវត្តិរូបខ្លះទៅ ។

សុវណ្ណៈ ចឹងកន្លែងមីងធ្វើការហ្នឹងគេហៅស្អីគេ កន្លែងស្រែអំបិលហ្នឹង?

វ៉នៈ គេហៅកំពង់ណុង ។

សុវណ្ណៈ អត់មានឈ្មោះអីផ្សេងទេ?

វ៉នៈ អត់ទេ នៅជិតវត្តកំពង់ណុង ។

សុវណ្ណៈ គេអត់មានហៅសហករណ៍នេះសហករណ៍នោះទេ?

វ៉នៈ ខាងសហករណ៍ខ្ញុំមិនបានដឹងទេ ព្រោះនៅដាច់ឆ្ងាយពីប្រជាជន ខ្ញុំនៅជិតសមុទ្រ ហើយភូមិប្រជាជននៅឆ្ងាយមិនដែលចេះទាក់ទងគ្នាទេ ។

សុវណ្ណៈ ចឹងការដ្ឋានមីងធ្វើស្រែអំបិលហ្នឹងមានគ្នាប្រហែលជាប៉ុន្មាននាក់កាលហ្នឹង?

វ៉នៈ ខ្ញុំដឹងថា មួយកងកន្លែងខ្ញុំនៅហ្នឹងកងវរយហ្នឹង ។

សុវណ្ណៈ កងវរយរបស់មីងមានគ្នាប៉ុន្មាននាក់?

វ៉នៈ មាន១០០នាក់ ។

សុវណ្ណៈ ហើយនៅក្រោមការគ្រប់គ្រងរបស់បងរឹម តែមួយ?

វ៉នៈ ចាស!តែមួយ ។

សុវណ្ណៈ ចឹងយើងធ្វើការរួមយើងហូបរួមគ្នាទាំងអស់មឹង?

វ៉នៈ ចាស ។

សុវណ្ណៈ រស់នៅរួមគ្នាដែរ?

វ៉នៈ ចាស ។

សុវណ្ណៈ យើងធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

វ៉នៈ អំបិលខែរងារចេះទៅព្រឹកហ្នឹងហើយ ។

សុវណ្ណៈ ចឹងយើងមានដឹងថាគេមានកំណត់ម៉ោងឲ្យយើងទេ?

វ៉នៈ ម៉ោង៧ ។

សុវណ្ណៈ ចឹងម៉ោង៧ចូលធ្វើការ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងយើងសម្រាកម៉ោងប៉ុន្មាន?

វ៉នៈ ម៉ោង៩ ។

សុវណ្ណៈ ចឹងម៉ោង៧ចូលម៉ោង៩ចេញ?

វ៉នៈ ម៉ោង៩សម្រាក ម៉ោង១១បានចេញ ។

សុវណ្ណៈ ចឹងម៉ោង១១សម្រាក?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលថ្ងៃចូលម៉ោងប៉ុន្មាន?

វ៉នៈ ចូលម៉ោង១ ម៉ោង៥ចេញ ។

សុវណ្ណៈ ចឹងការហូបចុកយ៉ាងម៉េចដែលពេលហ្នឹង?

វ៉នៈ ការហ្នឹងហូបរួមគ្នា ។

សុវណ្ណៈ យើងហូបបបរហូបបាយ?

វ៉នៈ ហូបបាយលាយពោត ។

សុវណ្ណៈ យើងហូបមួយថ្ងៃប៉ុន្មានពេល?

វ៉នៈ ហូបតែពីរពេលទេ ។

សុវណ្ណៈ ចឹងយើងធ្វើការមានថែមម៉ោងអីខ្លះទេមឹង?

វ៉នៈ នៅស្រែអំបិលពេលមេឃភ្លៀងបានត្រូវការយប់ តែអត់ភ្លៀងអត់ទេ ។

សុវណ្ណៈ យ៉ាងម៉េចភ្លៀងបានធ្វើពេលយប់?

វ៉នៈ ពេលភ្លៀងយប់ត្រូវការជញ្ជូនទាំងយប់ ។

សុវណ្ណៈ ហើយអំបិលហ្នឹងធ្វើពីខែណាដល់ខែណាដឹងទេ?

វ៉នៈ យើងពីខែ១២ខែ១ចាប់ផ្ដើមធ្វើហើយរហូតដល់ខែ៥ ។

សុវណ្ណៈ ចឹងមានន័យថាខែ១ចាប់ផ្ដើមធ្វើរហូតដល់ខែ៥ ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលចប់ធ្វើអំបិលហ្នឹងយើងធ្វើអីទៀត?

វ៉នៈ យើងឡើងទៅតាមចម្ការតាមភ្នំអីយើងដាំនេះដាំនោះហូប យើងដាំដំណាំអីហូប តែខែភ្លៀង ធ្វើលែងកើតហើយ ។

សុវណ្ណៈ ចឹងខែភ្លៀងយើងទៅធ្វើចម្ការវិញ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងខែប្រាំងយើងធ្វើអំបិល?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងធ្វើចម្ការហ្នឹងយើងច្រើនដាំអីគេ?

វ៉នៈ ចម្ការដាំពោតបន្តិចបន្តួចគ្រាន់តែហូបក្នុងអន្គភាព ។

សុវណ្ណៈ មឹងទៅដាំខាងណាវិញ?

វ៉នៈ ទៅដាំខាងភ្នំកែប ។

សុវណ្ណៈ ចឹងភ្នំវានៅក្នុងតំបន់របស់កែប?

វ៉នៈ ចាស ។

សុវណ្ណៈ ភ្នំវ៉ល្ង?

វ៉នៈ អត់ទេ នៅជិតភ្នំកែបហ្នឹងតែម្ដង ដាំនេះដាំនោះហូបបន្តិចបន្តួចដោះស្រាយអន្គភាពហ្នឹង ។

សុវណ្ណៈ ចឹងមឹងពេលហ្នឹងមានដែលជួបពីណាគេធំៗ ចុះមើលការខុសត្រូវប្រជាជននៅខាងស្រែអំបិលហ្នឹងទេ?

វ៉នៈ ស្រែអំបិលអត់មានពីណាចុះមកទេ នៅនេះមានមេការតែម្ដង យើងដឹងតែធ្វើ ។

សុវណ្ណៈ ចឹងអត់មានពីណាចុះមកមើលការងារអីទេ?

វ៉នៈ អត់មានទេ ។

សុវណ្ណៈ ចឹងអំបិលដែលយើងធ្វើបានគេបញ្ជូនទៅខាងណាវិញមឹង?

វ៉នៈ ដឹងយកទៅណា ដាក់ឃ្លាំងចឹងទៅពេលនេះឡានចូលដឹកចឹងទៅ ។

សុវណ្ណៈ មានដឹងថាគេដឹកយកទៅណាទៅណីខ្លះទេ?

វ៉នៈ អត់ទេ តែធ្វើ ធ្វើលើសផែនការកាលនោះ ។

សុវណ្ណៈ ចឹងយើងមានប្រជុំយ៉ាងម៉េចដែលពេលហ្នឹង ប៉ុន្មានថ្ងៃប្រជុំម្តងឬប៉ុន្មានអាទិត្យប្រជុំម្តង?

វ៉នៈ ប្រជុំបីថ្ងៃចឹងគេប្រជុំពួកតូចៗ

សុវណ្ណៈ បីថ្ងៃប្រជុំពួក?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលប្រជុំក្រុម?

វ៉នៈ ពេលមួយអាទិត្យអីចឹងគេប្រជុំក្រុមម្តង ។

សុវណ្ណៈ ចឹងពេលប្រជុំរួម?

វ៉នៈ ពេលប្រជុំរួមយូរដែលទំរាំបានប្រជុំ ។

សុវណ្ណៈ ប៉ុន្មានប្រហែលជាមួយខែទេ?

វ៉នៈ ចាស!មួយខែអី ។

សុវណ្ណៈ ប្រជុំពួកហ្នឹងច្រើនប្រជុំនៅពេលណា?

វ៉នៈ ប្រជុំពេលល្ងាច យើងហូបបាយហើយប្រជុំប្រហែលជាមួយម៉ោង ។

សុវណ្ណៈ ម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានមីង?

វ៉នៈ ម៉ោង៦ដល់ម៉ោង៧ចឹងទៅ ។

សុវណ្ណៈ ចឹងមានបដិសេធគេមិនទៅចូលប្រជុំអីខ្លះទេមីង?

វ៉នៈ អត់ទេ ។

សុវណ្ណៈ មូលហេតុអី?

វ៉នៈ ចឹងយើងធ្វើការមានគុណវិបត្តិមានការខ្វះខាតចឹង ពេលប្រជុំយើងលើក ។

សុវណ្ណៈ ចឹងមីងអត់មានគិតថា ធ្វើការហត់ហើយយប់ឡើងទៅប្រជុំទៀត មីងមានគិតចឹងទេ?

វ៉នៈ អត់ទេ វាត្រូវតែចឹងកាលហ្នឹង ។

សុវណ្ណៈ យើងមិនចាំបាច់ទៅប្រជុំ ព្រោះប្រជុំនិយាយដដែលៗមានគិតចឹងទេ?

វ៉នៈ អត់ទេ ព្រោះប្រជុំចឹង ម្យ៉ាងបានកសាងខ្លួនយើងបានល្អផង ហើយម្យ៉ាងយើងធ្វើខុសអីមិនដឹង បានអ្នកក្រៅគេជួយកសាងយើងដឹងកំហុស ។

សុវណ្ណៈ ហើយប្រជុំគេច្រើននិយាយរឿងអីគេខ្លះ?

វ៉នៈ និយាយពីរឿងការងារប្រចាំថ្ងៃ ចឹងយើងទៅធ្វើអំបិលទៅ យើងយកចិត្តទិកដាក់ដែរ ហើយយ៉ាងម៉េចអី ។

សុវណ្ណៈ មានគេប្រជុំស៊ុយទិចទៀនទេមីង?

វ៉នៈ ចាស!គេមានប្រជុំស៊ុយទិនទៀនដែលដូចថាមួយអាទិត្យឬកន្លះខែចឹងគេមានស៊ុយទិចទៀនគ្នាម្តង ។

សុវណ្ណៈ ស៊ុយទិចទៀនហ្នឹងច្រើននិយាយរឿងអីគេ?

វ៉នៈ រឿងយើងខ្លះងើបមិនទាន់ម៉ោងចឹងទៅ ដល់កន្លែងធ្វើការមិនទាន់ពេលចឹងទៅ គេស៊ុយទិចទៀនដើម្បីឲ្យបានស្រុះគ្នាចឹងទៅឬពេលមានមេឃភ្លៀងចឹងទៅយើងត្រូវយកចិត្តទុកដាក់ឲ្យទាន់គ្នាចឹងទៅ ខ្លះគ្នារឿងយឺយាគដែរ ធ្វើការវាមិនសូវស្វាហាប់ដូចគ្នាទេ ។

សុវណ្ណៈ ចឹងមីងមានគេស៊ុយទិចទៀនខ្លះទេ?

វ៉នៈ ខ្ញុំមិនឲ្យស៊ុយទិចទៀនទាន់ទេ ។

សុវណ្ណៈ ម៉េចចឹងមីង?

វ៉នៈ ខ្ញុំធ្វើឲ្យបានទៀតទាត់ចឹងឯង ។

សុវណ្ណៈ ចឹងគេមានដែលស៊ុយទិចទៀនមីងទេ?

វ៉នៈ គេមិនដែលទេ គេអត់មានមើលឃើញកំហុសយើងដែរ ខ្ញុំធ្វើអីមិនមានស៊ុយទិចទៀន ។

សុវណ្ណៈ ចឹងកាលហ្នឹងយើងគិតតែធ្វើការមួយមុខទេ?

វ៉នៈ ចាស ។

សុវណ្ណៈ គិតតែខំធ្វើការទៅ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលធ្វើការហ្នឹងមីងមានដែលជួបបញ្ហាលំបាកអីខ្លះទេ?

វ៉នៈ ខ្ញុំនៅកន្លែងហ្នឹងដូចជាមិនសូវលំបាក គ្រាន់តែក្តៅបន្តិច វាធ្វើចំខែក្តៅ ដល់ធ្វើទៅបានអំបិលច្រើនៗចឹងទៅ អត់មានលំបាកអីទេ ។

សុវណ្ណៈ ចឹងនៅក្នុងពេលហ្នឹងយើងមានទឹកនាបងប្អូនទឹកនាបងប្អូនអីខ្លះទេ?

វ៉នៈ ទឹកដូចគ្នាតែមកមិនបាន ។

សុវណ្ណៈ ចឹងយើងមានដែលសុំគេទៅលេងផ្ទះទេ?

វ៉នៈ អត់ ។

សុវណ្ណៈ ចឹងអត់មានដែលសុំសោះតែម្តង?

វ៉នៈ ចាស!ទោះបីសុំបានក៏មិនដឹងមានអីជិះមកដែរ ឆ្ងាយណាស់គ្មានឡានចេញចូល ។

សុវណ្ណៈ ចឹងពេលយើងនឹកឪពុកម្ដាយនឹកបងប្អូនធ្វើយ៉ាងម៉េចទៅចឹង?

វ៉នៈ អត់ដែលបានមកទេខ្ញុំ ជូនសំបុត្រអីចឹង ដូចមានអ្នកសេដ្ឋកិច្ចមកបន្លែតាមខេត្តចឹងទៅយើងផ្ញើរតាមគេឲ្យបោះឲ្យទៅ ដល់ពេលខ្ញុំបានទៅជួបគាត់ គាត់ប្រាប់ថាមិនដែលបានឃើញដែរកាលហ្នឹង ។

សុវណ្ណៈ មិនដែលឃើញសំបុត្រមីងភ្ញើរឲ្យ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងសំបុត្រយើងខស្សាហ៍សរសេរទេ?

វ៉នៈ សរសេរបានពីរដង គេមិនត្រូវការមកដល់ខេត្តយើងឆ្ងាយពេក អ្នកយកបន្លែអីគេច្រើនយកកំពតហ្នឹង ។

សុវណ្ណៈ ចឹងមីងកាលហ្នឹងធ្វើការខាងអំបិលមួយទេ មីងអត់មានទៅណាទៅណីផ្សេងទៀតទេ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងអត់មានផ្លាស់ទៅនេះទៅនោះទេ?

វ៉នៈ អត់មានទេ ។

សុវណ្ណៈ ចឹងធ្វើរហូតដល់ពេលកងទ័ពវៀតណាមវាយចូលមកមីង?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលវៀតណាមវាយចូលមក មីងរត់ទៅណាវិញ?

វ៉នៈ ខ្ញុំរត់មកឡើងភ្នំនេះឯង រត់ច្រើនដំណាក់ណាស់ខ្ញុំ បេះតែរត់តាមគេមក ដល់មកដល់ភ្នំថៃឡើងដល់ដីថៃ ។

សុវណ្ណៈ ចឹងកាលពីដំបូងរត់ចេញពីកំពតហ្នឹង រត់តាមផ្លូវណា?

វ៉នៈ ខ្ញុំរត់មកខាងកំពង់ចាមមក ។

សុវណ្ណៈ រត់មកខាងកំពង់ចាមវិញ?

វ៉នៈ ចាស!រត់ចេញពីហ្នឹងព័ទ្ធៗខ្ញុំមិនស្គាល់ទេ ខ្ញុំរត់តាមគេមិនដឹងជាខាងណាខាងណី ។

សុវណ្ណៈ ចឹងរត់តាមទ័ព?

វ៉នៈ រត់តាមទ័ព នារីស្រែអំបិលហ្នឹងច្រើន បេះតែចូលទៅនេះចូលទៅនោះដាច់អស់នៅសល់គ្នាប៉ុន្មាននាក់ ទៅដល់លើភ្នំតាមគេឯងទៅ ។

សុវណ្ណៈ មីងទៅដល់ណាខ្លះ មុនដំបូងមីងរត់ទៅកន្លែងណា?

វ៉នៈ ខ្ញុំដំបូងមិនត្រង់ណាត្រង់ណី ខ្ញុំមិនស្គាល់ផង រត់តាមតែគេ គេថាឡើងភ្នំក៏ឡើងហ្នឹងគេទៅ ។

សុវណ្ណៈ ចឹងកាលរត់ហ្នឹង យើងដើរតាមផ្លូវឬមួយយើងរត់ក្នុងព្រៃ?

រ៉នៈ	រត់ដំបូងតាមផ្លូវ  ដល់យូរៗទៅគេខ្លាចគេមិនហ៊ានរត់តាមផ្លូវ  ចេះតែរុកព្រៃមកដឹងថាអត់ស្គាល់ទៀតខ្ញុំវង្វេងទៀត ចូលព្រៃវង្វេងតែម្តងមិនដឹងជាណាណី ។

សុវណ្ណៈ	ចឹងដើរក្នុងព្រៃរហូតទៅ?

រ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងកាលហ្នឹងយើងម៉េចបានជារត់តាមគេចឹងមីង អត់មានរត់ទៅនៅស្រុកកំណើតវិញចឹង?

រ៉នៈ	ខ្ញុំមិនហ៊ានទៅទេ គេចូលយើងចេញមកចូលចឹងហើយ យើងចូលទៅវិញ គេសុទ្ធថាយកទៅសម្លាប់ចោល ។

សុវណ្ណៈ	គេថាខាងណាយកទៅសម្លាប់ចោល ខាងវៀតណាម?

រ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងគេប្រាប់ថា បើយើងនៅខាងវៀតណាមគេយកទៅសម្លាប់ចោល?

រ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងពេលរត់ហ្នឹងយើងហូបចុកយ៉ាងម៉េច?

រ៉នៈ	យើងហូបក្តួច  មុនដំបូងមានអង្ករហូបខ្លះ  ដល់យើងរត់យូរៗដាច់អង្ករនាំគ្នាជីកក្តួចដំឡូងចឹងទៅ  ហូបចេកស្ងោចឹងទៅទំរាំបានឡើងទៅដល់ដីថៃ រត់ៗជួបទ័ពទេ ពួកខ្ញុំនោះ ។

សុវណ្ណៈ	ចឹងកាលហ្នឹងរត់ដំបូងរត់តែក្រុមនារី?

រ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងក្រោយមក មកជួបទ័ព?

រ៉នៈ	ចាស!ជួបទ័ព ទ័ពហ្នឹងគេត្រូវឡើងភ្នំទៀត ។

សុវណ្ណៈ	ជួបទ័ពនៅកន្លែងណាដំបូង?

រ៉នៈ	គេហៅវាស្អីទេ ខ្ញុំមិនបានសួរគេទៀតណា ។

សុវណ្ណៈ	ចឹងជួបទ័ពតាមផ្លូវទេ?

រ៉នៈ	ចាស! ជួបហ្នឹងគេកំពង់ដាក់ខ្សែឡើងលើភ្នំ បានជួបគេចឹងបានឡើងទៅជាមួយគេទៅ ។

សុវណ្ណៈ	ពេលរត់ឆ្នាំ៧៩ហ្នឹង      មីងរត់មកដល់ខាងណាលើភ្នំហ្នឹងមកដល់១០០១-១០០២-១០០៣ កាលហ្នឹង?

រ៉នៈ	ខ្ញុំមកដល់១០០១ នៅទន្លេល្ពៅ ។

សុវណ្ណៈ	ចឹង១០០១យើងរត់ឡើងតាមច្រកណាមីង?

រ៉នៈ	ច្រកភ្នំរូង ។

សុវណ្ណៈ	ចឹងកាលហ្នឹងយើងមានផ្លូវឡើងត្រឹមត្រូវឬយើងឡើងរបៀបយ៉ាងម៉េច?

រ៉ន:		កាលហ្នឹងមានផ្លូវទូកៗៗ  គេឡើងមុនចឹងរៀងទូកៗយើងចេះតែឡើងដែលចូលក្នុងរូងហ្នឹង បានទៅដល់ចេញទៅវាល កន្លែងហ្នឹងមានរូងមែនបានគេហៅភ្នំរូង ។

សុវណ្ណៈ	ចឹងដំបូងយើងចូលទៅក្នុងរូងភ្នំសិន?

រ៉ន:		ចាស! យើងឡើងប្រាំងចឹងទៅ ទៅដល់លើហ្នឹង មានរូងមួយចូលក្នុងរូងបានឆ្ងាយ បានចេញឆ្ងាយទៅវាល ។

សុវណ្ណៈ	ចឹងកាលហ្នឹងមានគោងវ៉ល្លអីឡើងទេមីង?

រ៉ន:		មានគោងប្រជ្រែតគ្នាឡើងគោង ។

សុវណ្ណៈ	ចឹងបើមានអ្នកគោងមិនជាប់មិនធ្លាក់មកស្លាប់ទេ?

រ៉ន:		ប្រយ័ត្នមានធ្លាក់ខ្លះដែរ ។

សុវណ្ណៈ	ចឹងមានស្លាប់ច្រើនដែរ?

រ៉ន:		មានស្លាប់ច្រើនដែលតាមនេះ  អ្នកអត់មានបាយហ្នឹងដល់ពេលទៅហូបបាយក៏ស្លាប់ដោយសារបាយទៀត ។

សុវណ្ណៈ	ម៉េចចឹងកាលហ្នឹងមីង?

រ៉ន:		ដូចថាពោះយើងដាច់បាយយូរចឹង ទៅដល់ហូបបាយហល់បាយស្លាប់ក៏មាន ។

សុវណ្ណៈ	ចឹងពេលធ្វើដំណើរតាមផ្លូវមកមានឃើញមនុស្សស្លាប់ខ្លះទេ?

រ៉ន:		ខ្ញុំដើរអត់មានជួបទេ ។

សុវណ្ណៈ	មានអ្នកឈឺស្លាប់តាមផ្លូវខ្លះទេ?

រ៉ន:		មានឈឺគ្រុនបន្តិចបន្តួចតែអត់ស្លាប់ទេ ។

សុវណ្ណៈ	ចឹងកាលមកដល់១០០៣ហ្នឹង មកដល់ឆ្នាំណាកាលហ្នឹង?

រ៉ន:		ឆ្នាំប៉ុន្មានទេ កូនខ្ញុំកើត កូនខ្ញុំអាប្រុសមិញនេះ ។

សុវណ្ណៈ	យើងរត់នៅក្នុងព្រៃយូរទេ?

រ៉ន:		ខ្ញុំ៧៩ បានចេញដល់៨០ បានឡើងដល់ភ្នំ ខ្ញុំមកនៅ១០០៣អាចឆ្នាំ៨៤ ។

សុវណ្ណៈ	ចឹងខ្ញុំចង់និយាយថា មកដល់១០០១សិន?

រ៉ន:		មកដល់១០០១ឆ្នាំ៨០ ។

សុវណ្ណៈ	ចឹងមានន័យថា  យើងចំណាយពេលនៅក្នុងព្រៃតំបន់ផ្សេងៗចង់មួយឆ្នាំដែលមីង  ទំរាំមកដល់១០០១?

រ៉ន:		ចាស ។

សុវណ្ណៈ	ចឹងរយៈពេលជិតមួយឆ្នាំហ្នឹង យើងនៅក្នុងព្រៃសុទ្ធតែម្តងឬមួយមាននៅតាមភូមិអីដែរ?

រ៉ន: មុនដំបូងនៅក្នុងភូមិទេ ។

សុវណ្ណ: ចឹងដំបូងក្នុងភូមិ?

រ៉ន: ចាស!ខ្ញុំចូលព្រៃប្រហែលជាបួនខែទេបីខែអីហ្នឹង ឡើងភ្នំហើយ ។

សុវណ្ណ: ចឹងអាចថាចុងឆ្នាំ៧៩?

រ៉ន: ចាស ។

សុវណ្ណ: ចឹងចុង៧៩មកដល់ភ្នំហើយ?

រ៉ន: ចាស ។

សុវណ្ណ: ចឹងមកដល់១០០១ហ្នឹងមានដឹងថាពីណាគ្រប់គ្រង?

រ៉ន: នៅ១០០១ កាលនោះមានតាដុស នៅឃ្លាំង ។

សុវណ្ណ: ចឹងតាដុស គាត់កាន់ខាងឃ្លាំង?

រ៉ន: ចាស ។

សុវណ្ណ: ឃ្លាំងហ្នឹងឃ្លាំងអីគេ?

រ៉ន: ឃ្លាំងអង្ករសម្រាប់ទុកអីវ៉ាន់ហូប ឥវ៉ាន់គ្រប់មុខ មានត្រីខ មានស្ករ មានប៊ីចេង ។

សុវណ្ណ: ចឹង១០០១ហ្នឹងខាងកងពលណាគេគ្រប់គ្រង?

រ៉ន: ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំឡើងទៅខ្ញុំមិនបានទៅនៅក្នុងកងពលអីទេ ខ្ញុំនៅក្នុងភូមិគេហៅភូមិប្រជាជន ។

សុវណ្ណ: ភូមិប្រជាជនតែនៅក្នុងបរិវេនរបស់កងពលដែលទេ ១០០១ហ្នឹង?

រ៉ន: នៅក្នុងភូមិមានតា "អាន" ជាអ្នកគ្រប់គ្រង ។

សុវណ្ណ: តាអាន?

រ៉ន: ចាស!ខាងទ័ពគេផ្សេង ។

សុវណ្ណ: តាអាន ហ្នឹងគាត់គ្រប់គ្រងខាងអីគេ?

រ៉ន: ខាងប្រជាជន ។

សុវណ្ណ: តាអាន ហ្នឹងឈ្មោះពេញស្អីគេ?

រ៉ន: តាអាន មិនដឹងជាស្អីអានទេ ខ្ញុំមិនស្គាល់ផង ។

សុវណ្ណ: គាត់មកពីខាងណាតាអាន ហ្នឹង?

រ៉ន: តាអាន ហ្នឹងមិនជាគាត់មកពីខាងណាទេ គាត់ឡើងភ្នំដែលដល់លើហ្នឹង ប្រជាជនដូចពួកខ្ញុំអត់មានកងអត់មានក្រុមចឹង គេប្រមូលដាក់មួយដុំមកគេដាក់ឈ្មោះថា ភូមិតាអាន ចឹងតែម្តង ។

សុវណ្ណៈ ចឹងហៅភូមិតាអាន ចឹងតែម្ដង?

វ៉នៈ ចាស ។

សុវណ្ណៈ កាលទៅដល់ដំបូង១០០១ហ្នឹង?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងតាអាន ខាងទ័ពឬខាងប្រជាជន?

វ៉នៈ ខាងប្រជាជន គាត់រាងចំណាស់ហើយ ។

សុវណ្ណៈ តែមានដឹងថា គាត់មកពីខាងណាខាងណីទេ អ្នកស្រុកខាងណា?

វ៉នៈ មិនដឹងជាខាងណាទេ តាអាន ខ្ញុំអត់មានបានដឹងដែរ ។

សុវណ្ណៈ ព្រោះថា គាត់ជាអ្នកប្រមូលប្រជាជនមកគ្រប់គ្រងទាល់តែគាត់មានអំណាចអីខ្លះដែរ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងទៅដល់១០០១ជួបតាអាន ក៏ប្រមូលប្រជាជនមកនៅដាក់ឈ្មោះភូមិតាអានទៅ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងពេលនៅ១០០១ហ្នឹង យើងហូបចុកយ៉ាងម៉េចមីង រស់នៅយ៉ាងម៉េចដែលជីវភាព?

វ៉នៈ ជីវភាពអត់មានអីទេ ភូមិប្រជាជនហ្នឹងមានរបបបើកដូចទ័ពដែរ ពេលខែរដូវបុណ្យទានអីចឹង មានរបបគេបើកឲ្យហូបមិនអស់ទេ មានអង្ករដំណើបអង្ករខ្សាយ មានប្រេងមានមីមានត្រីខមានអីចែកតាមរបបមនុស្ស ។

សុវណ្ណៈ ហើយរបបហ្នឹងគេបើករបៀបយ៉ាងម៉េច គេបើមួយអាទិត្យម្ដងឬមួយខែម្ដង?

វ៉នៈ គេបើកប្រចាំរាល់ថ្ងៃហ្នឹង គេបើកមួយខែម្ដង បើមានពេលរដូវបុណ្យអីគេបើកតាមហ្នឹងទៀត បុណ្យមួយៗគេបើកឲ្យច្រើនជាងយើងបើកប្រចាំខែ អង្ករអី កំណត់ថាថ្ងៃណាបើកថ្ងៃហ្នឹងបើកហើយ បើកអង្ករបើកត្រីខ បើកប្រហុក មានមួយចប់ ។

សុវណ្ណៈ របបមានត្រីខ របបផ្សេងៗហ្នឹងគេបើកមួយអាទិត្យម្ដងឬបើកមួយខែម្ដង?

វ៉នៈ អាហ្នឹងកន្លះខែម្ដង ។

សុវណ្ណៈ ចឹងអង្ករ?

វ៉នៈ អង្ករក៏ដូចគ្នា តែបើកអង្ករបើកម្ហូបហើយ ។

សុវណ្ណៈ ហើយអង្ករត្រីខទាំងអស់ហ្នឹងយើងបានមកពីខាងណា?

វ៉នៈ ដឹងថាមកពីខាងណាដែរ ដល់ពេលគេបើកគេចេះតែហៅទៅ យើងដឹងតែយក ។

សុវណ្ណៈ មិនបានដឹងថាគេបានមកពីខាងណាទេ?

វ៉នៈ ចាស!ដឹងថាខាងឃ្លាំងយើងបើកឲ្យ ។

សុវណ្ណៈ ចឹងដឹងថាខាងឃុំគេបើកឲ្យ?

វ៉នៈ ចាស! ខាងឃុំគេហៅយកចឹងតែម្តង ។

សុវណ្ណៈ ចឹងនៅភូមិតាអាន ហ្នឹងកាលហ្នឹងមានប៉ុន្មានគ្រួសារមីង?

វ៉នៈ ខ្ញុំមិនបានដឹងដែរ ព្រោះលែងចង់ដឹងអីទាំងអស់ហើយឲ្យតែបានរស់ លែងចង់ដឹងចង់អី ព្រោះទៅដល់នោះនៅមានជួបការលំបាកច្រើនដែរ កងទ័ពនៅតែមានវាយគ្នានៅខាងលើ នោះឯង ខ្ញុំលែងចង់ដឹងអីហើយខ្ញុំ ។

សុវណ្ណៈ ចឹងយើងមានរកស៊ីលក់ដូរអីខ្លះឲ្យខាងថៃខ្លះឬមានស៊ីឈ្នួលឲ្យថៃខ្លះទេ?

វ៉នៈ អត់ទេ ។

សុវណ្ណៈ អត់ទាន់ទេ?

វ៉នៈ ចាស! ខ្ញុំមិនដែលហ៊ានចេញសោះ ។

សុវណ្ណៈ ចឹងមីងការជាមួយពូការឆ្នាំណា?

វ៉នៈ ខ្ញុំការឆ្នាំ៨០ហ្នឹង ពេលឡើងទៅដល់ភ្នំ ។

សុវណ្ណៈ ចឹងឆ្នាំ៨០ការជាមួយពូទៅ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងកាលពូខាងទ័ពកាលហ្នឹង?

វ៉នៈ គាត់ខាងទ័ពតែគាត់បោះបង់ចោល ។

សុវណ្ណៈ មេ៉ចបានជាគាត់បោះបង់ចោល?

វ៉នៈ គាត់រត់បែកគ្នា គាត់ឈប់មានគេកើយ គាត់ចូលទៅរស់នៅក្នុងភូមិហ្នឹងដែលទៅ ។

សុវណ្ណៈ ចឹងកាលពីមុនពីទ័ពខាងណា ទ័ពខាងកងពលណា?

វ៉នៈ ខ្ញុំអត់ដឹងដែរ គាត់ថាគាត់រត់បែកគ្នាអស់ គាត់ទៅនៅខាងណានោះ ដល់ពេលឃ្មួនបុកមក គាត់រត់មក ។

សុវណ្ណៈ គាត់ជាអ្នកស្រុកណាមីង?

វ៉នៈ គាត់នៅខាងស្រុកជីក្រែង ។

សុវណ្ណៈ កំពង់ចាម?

វ៉នៈ អត់ទេ ខាងសៀមរាបយើងនេះ ស្រុកជីក្រែង ។

សុវណ្ណៈ តែពេលការហ្នឹងគាត់នៅជាទ័ពនៅឡើយទេ?

វ៉នៈ អត់ទេ ចេញហើយ ។

សុវណ្ណៈ មូលហេតុអីបានចេញ កាលហ្នឹង?

រ៉ន: គាត់រត់បែកគ្នាពីនេះទៅបាត់មេបាត់កើយអស់ទៅ គាត់ឈប់ធ្វើទៅ ។

សុវណ្ណ: តែពីមុនគាត់ជាទ័ពខាងខ្មែរក្រហមគ្រប់គ្រងទេ?

រ៉ន: ចាស ។

សុវណ្ណ: ចឹងពេលរត់មកនេះគាត់ឈប់ធ្វើទៅ?

រ៉ន: គាត់ឈប់ទៅ រត់បែកគ្នាអស់ ។

សុវណ្ណ: ចឹងមានដឹងថា មូលហេតុអីឈប់ទេមីង?

រ៉ន: គាត់ថា យូរៗគាត់អស់មានចិត្តចង់ធ្វើទ័ព ឃើញមានកន្លែងគេប្រមូល ហើយគាត់ហ្នឹងពិការផង គាត់ខ្សោយ ។

សុវណ្ណ: គាត់ពិការអីគេ?

រ៉ន: គាត់ពិការត្រូវកនេះ ។

សុវណ្ណ: ដោយសារអីគេ?

រ៉ន: ត្រូវគ្រាប់ ។

សុវណ្ណ: ត្រូវគ្រាប់ពេលវាយជាមួយខាងណា?

រ៉ន: ពេលវាយជាមួយខាងទាហាន លន់ នល់ កាលហ្នឹង ។

សុវណ្ណ: វាយជាមួយទាហាន លន់ នល់?

រ៉ន: ចាស ។

សុវណ្ណ: មិនមែនវាយជាមួយទាហានវៀតណាមទេ?

រ៉ន: ចាស ។

សុវណ្ណ: ចឹងមីង១០០១នៅបានរយៈពេលប៉ុន្មានឆ្នាំប៉ុន្មានខែដែរ ហើយយើងចេញទៅខាងណាទៀត?

រ៉ន: ខ្ញុំនៅបានពីរឆ្នាំ ខ្ញុំចេញមកខាង១០០៣វិញ ។

សុវណ្ណ: ចឹងអាចថាឆ្នាំ៨១មីង?

រ៉ន: ឆ្នាំ៨២ ។

សុវណ្ណ: ចឹង៨២មីងចេញមកខាង១០០៣?

រ៉ន: ចាស ។

សុវណ្ណ: ចឹងនៅ១០០៣ហ្នឹងគេហៅអី មានឈ្មោះអីដូច១០០១គេហៅទន្លេល្អៅចឹង?

រ៉ន: ចាស ។

សុវណ្ណ: ចុះ១០០៣?

វ៉ន: ខ្ញុំមកនៅ១០០៣ខ្លះគេហៅស៊ឹងចាន់ ។

សុវណ្ណ: ចឹងស៊ឹងចាន់?

វ៉ន: ចាស ។

សុវណ្ណ: យ៉ាងម៉េចបានជាគេដាក់ឈ្មោះ ស៊ឹងចាន់?

វ៉ន: ខ្ញុំមិនបានដឹងដែរ ។

សុវណ្ណ: ចឹងស៊ឹងចាន់ហ្នឹងនៅក្នុងដីខ្មែរឬមួយដីថៃមឹង?

វ៉ន: ដីថៃ ។

សុវណ្ណ: ដីថៃឥឡូវនេះ?

វ៉ន: ចាស ។

សុវណ្ណ: ដីថៃ ប្រហែលជាចូលប៉ុន្មានគីឡូឆ្ងាយឬជិត?

វ៉ន: កន្លែងខ្ញុំនៅហ្នឹងឆ្ងាយពីស៊ឹងចាន់ហ្នឹង គេហៅដើមរកា កាលខ្ញុំនៅកន្លែង«ឆប»ថៃ ហើយស៊ឹងចាន់នៅក្រោមនេះ នៅជិតជណ្ដើរ៥០ជិតអីនេះ ។

សុវណ្ណ: ចឹងស៊ឹងចាន់វាមានទឹកអីទេ?

វ៉ន: ចាស ៗ !មានទឹកមានស៊ឹងមានត្រាវមានអី ខ្ញុំនៅកន្លែងស៊ឹងចាន់ហ្នឹងប្រហែល១០ថ្ងៃចឹងគេរើឲ្យទៅនៅកន្លែងដើមរកាហ្នឹង ហ្នឹងជិតថៃហើយហ្នឹង ។

សុវណ្ណ: ចឹងកន្លែងដើមរកាហ្នឹងនៅក្នុង១០០៣ដែលទេ?

វ៉ន: ចាស ។

សុវណ្ណ: មឹងស៊ឹងចាន់ហ្នឹងទឹកហូរមកពីភ្នំឬមួយយ៉ាងម៉េច?

វ៉ន: ខ្ញុំមិនបានមកដល់ទេ កន្លែងស៊ឹងចាន់ហ្នឹងនោះ ។

សុវណ្ណ: តែខ្ញុំចង់ដឹងថា ស៊ឹងចាន់ហ្នឹងជារបៀបស៊ឹងដីទន្លេឬមួយថ្ម?

វ៉ន: ថ្ម ។

សុវណ្ណ: ចឹងថ្មទេ?

វ៉ន: ចាស!គេថាថ្មទេ ខ្ញុំមិនដែលបានចូលមកដល់ ។

សុវណ្ណ: ធំទេ មឹងកាលហ្នឹង?

វ៉ន: ខ្ញុំមិនដែលឃើញដែរ ។

សុវណ្ណ: ចឹងទឹកយើងបានមកពីណាប្រើមឹងកាលហ្នឹង ពេលនៅ១០០៣ ចង់ប្រើទឹកអីហ្នឹង?

វ៉ន: ទឹកអូរ ។

សុវណ្ណ: អូរអី?

រ៉ន: មិនដឹងជាអូរអីទេ អូរហ្នឹងមានថ្មតូចៗដល់កន្លែងដើមរកាហ្នឹងមានទឹកជ្រោះ មានទឹកជុបប្រើមិនចេះអស់ គេយកទៅនៅហ្នឹងស្រួលប្រើទឹក ។

សុវណ្ណៈ ចឹងនៅ១០០៣ហ្នឹងពីណាគេគ្រប់គ្រងពេលហ្នឹង?

រ៉ន: កាលនៅ១០០៣ ខ្ញុំនៅជាមួយតាដុស ។

សុវណ្ណៈ ចឹងតាដុស ដដែលទេ?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងម៉េចបានយើងចេញពី១០០១កាលឆ្នាំ៨២ហ្នឹង?

រ៉ន: កាលហ្នឹងកងទ័ពវៀតណាមវាយ ។

សុវណ្ណៈ ចឹងគេវាយដល់នេះទៀត?

រ៉ន: ចាស!វាយដល់ថៃ ។

សុវណ្ណៈ ចឹងគេវាយយើងរត់មក?

រ៉ន: ចាស ។

សុវណ្ណៈ រត់មកខាង១០០៣មក?

រ៉ន: ចាស!គេជម្លៀសមីងៗមកអស់ ទុកតែពូៗ នៅចាំឃ្លាំង ។

សុវណ្ណៈ ចឹងមានន័យថា កាលឆ្នាំ៨២ហ្នឹង មិនទាន់មកទាំងអស់ទេ នៅសល់ពូខាងទ័ពហ្នឹងនៅប្រចាំ១០០១ហ្នឹង?

រ៉ន: គេអ្នកខ្លាំងៗគេមិនទាន់ការ គេនៅគ្រួសារខ្ញុំពិកាខ្សោយមកដែរ ។

សុវណ្ណៈ ចឹងមានន័យថាគេទុកតែទ័ពទេ?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងឆ្នាំ៨២ខាងកងទ័ពវៀតណាមវាយហ្នឹងយើងនៅសល់ទ័ព ចំពោះមីងៗឬអ៊ំចាស់ៗចេញទៅដែលធ្វើអីមិនកើតគេជម្លៀសទៅខាង១០០៣?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងនៅ១០០៣គេនៅតែបើករបបឲ្យយើងហូបធម្មតា?

រ៉ន: ចាស!នៅតែបើកចឹង ។

សុវណ្ណៈ ចឹងមានអ្នកខ្លះរកស៊ីជួញដូរអីខ្លះជាមួយថៃទេ?

រ៉ន: ខ្ញុំមិនបានដឹងដែលហ្នឹង ។

សុវណ្ណៈ ចឹងមានស៊ីឈ្នួលកាប់ដីឡូងអីខ្លះមានទេ?

រ៉ន: អត់ហ៊ានដើរចោលផ្ទះទេ មិមហ៊ានដើរចោលកន្លែងទេ ។

សុវណ្ណៈ មូលហេតុអីមិនហ៊ានដើរចោលកន្លែង?

រ៉ន: ខ្លាចទៅដល់ហ្នឹងក៏នៅមិនទាន់ស្ងាត់ដែរ នៅតែប្រយ័ត្នជាប់ ។

សុវណ្ណៈ ប្រយ័ត្នរឿងអីគេ?

រ៉ន: ប្រយ័ត្នរឿងគេវ៉ាយហ្នឹង ។

សុវណ្ណៈ រឿងខាងវៀតណាមវ៉ាយហ្នឹង?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងមីងមានដឹងថា ខាងកងពលណាគេគ្រប់គ្រងនៅ១០០៣ហ្នឹង?

រ៉ន: ខ្ញុំមិនបានដឹងទេ មិនដឹងជាកងពលណា ។

សុវណ្ណៈ ចឹងអត់បានស្គាល់ថា ជាកងពលណាទេ?

រ៉ន: ចាស!ខ្ញុំនៅកន្លែងឃ្លាំងហ្នឹងខ្ញុំដឹងថានៅម្តុំកន្លែងខ្ញុំហ្នឹង គេនៅកន្លែងផ្សេងឆ្ងាយខ្ញុំមិនដឹងទេ ។

សុវណ្ណៈ ចឹងអ្នកគ្រប់គ្រងឃ្លាំងមីងគាត់ឈ្មោះ តាដុស?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងសព្វថ្ងៃកាត់នៅរស់ឬគាត់ខូចហើយមីង?

រ៉ន: ខ្ញុំអត់ដឹងដែលខ្ញុំបែកគ្នាមើលតាំងពីខ្ញុំចុះមកដីខ្មែរហ្នឹង បែកគ្នារហូតមិនដឹងជាទៅណាទៅណីទេ ខ្ញុំមិនបានដឹង ។

សុវណ្ណៈ ចឹងយើងនៅ១០០៣នៅរហូតឬមួយយើងរត់ទៅណាទៀត?

រ៉ន: ដល់ពេល១០០៣ហ្នឹង ខ្ញុំចេញពី១០០៣ ខ្ញុំនៅអូរត្រាវ គេមានកើតជំរំនៅអូរត្រាវ ជំរំកាកក្របាទ ហើយខ្ញុំចេញពី១០០៣ហើយ ។

សុវណ្ណៈ យ៉ាងម៉េចបានគេយកទៅដាក់អូរត្រាវ?

រ៉ន: ដីថៃគេដាក់ចឹង ។

សុវណ្ណៈ ចឹងជំរំអូរត្រាវនៅដីថៃទេ?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងយើងនៅដីថៃហ្នឹង នៅឆ្ងាយគីឡូជ្រៅទេ ចូលទៅឆ្ងាយទេ?

រ៉ន: មិនសូវឆ្ងាយទេ ។

សុវណ្ណៈ ប្រហែលជាប៉ុន្មានគីឡូពីដីខ្មែរបានទៅដល់ជំរំអូរត្រាវហ្នឹង?

រ៉ន: បើដើរប្រហែលជាមួយថ្ងៃដែលដឹង ។

សុវណ្ណៈ ចឹងយើងចេញពី១០០៣ទៅនៅជំរំអូរត្រាវនៅឆ្នាំណា?

រ៉ន: អត់មានបានចាំឆ្នាំផង មិនដឹងថាគេកើតជំរំហ្នឹងឆ្នាំណា ខ្ញុំភ្លេចដែរ ។

សុវណ្ណៈ	ចឹងយើងនៅ១០០៣ហ្នឹង នៅបានយូរទេ?

វ៉ន:	នៅបានមួយឆ្នាំ ។

សុវណ្ណៈ	ចឹងនៅបានប្រហែលជាមួយឆ្នាំដែលបានទៅនៅអូរត្រាវ?

វ៉ន:	ចាស ។

សុវណ្ណៈ	ចឹងនៅអូរត្រាវហ្នឹងមានពីណាគេគ្រប់គ្រង?

វ៉ន:	ខ្ញុំមិនស្គាល់ដែលប្រធាននៅហ្នឹង ប្រធានជំរំគេមិនដឹងជាពីណា ។

សុវណ្ណៈ	ចឹងនៅក្នុងជំរំអូរត្រាវហ្នឹងមានប្រជាជនច្រើនទេ?

វ៉ន:	មានច្រើន ខ្ញុំនៅក្នុងសង្កាត់ពូឃិន ពូខ្ញុំហ្នឹង ។

សុវណ្ណៈ	ពូឃិន?

វ៉ន:	ពូឃឹម ។

សុវណ្ណៈ	ឃឹម?

វ៉ន:	ចាស!ពូឃឹម ហ្នឹងពូខ្ញុំហើយ មួយសង្កាត់ខ្ញុំគាត់អ្នកគ្រប់គ្រង ខ្ញុំមិនបានដឹងថាមានប៉ុន្មានសង្កាត់ទេ ។

សុវណ្ណៈ	ពូឃឹម ហ្នឹងត្រូវជាពូមីងបង្កើត?

វ៉ន:	ចាស!ពូជីដូនហើយ ។

សុវណ្ណៈ	មានប្រហែលជាប៉ុន្មានសង្កាត់កាលហ្នឹង?

វ៉ន:	ខ្ញុំអត់ដឹងដែរ ។

សុវណ្ណៈ	ចឹងយើងមានចាយលុយកាក់ទេ ពេលនៅជំរំហ្នឹង ពេលនៅជំរំអូរត្រាវហ្នឹង?

វ៉ន:	ពេលនៅជំរំហ្នឹងមានចាយខ្លះៗហើយ ចាយតែយើងគ្មានមុខរបររកអីហ្នឹងគេដង ។

សុវណ្ណៈ	គេចាយលុយអីគេ?

វ៉ន:	ចាយៗ!លុយបាត ។

សុវណ្ណៈ	ចឹងយើងខ្មែរម៉េចបានជាមិនចាយលុយខ្មែរ យ៉ាងម៉េចបានជាចាយលុយបាតវិញ?

វ៉ន:	កាលហ្នឹងយើងមិនទាន់មានទេ លុយខ្មែរមិនទាន់មានទេ ។

សុវណ្ណៈ	ចឹងមីងចាប់ផ្ដើមលុយខ្មែរយើងចាប់ពីពេលណាមក?

វ៉ន:	លុយយើងសព្វថ្ងៃ ។

សុវណ្ណៈ	បាទ ។

វ៉ន:	ស្គាល់ កាលឆ្នាំ១៩៩៨ ។

សុវណ្ណៈ	ចឹងទើបស្គាល់៩៨ទេ?

វ៉ន: ចាស ។

សុវណ្ណ: ចឹងស្គាល់ពេលយើងមានសមាហរណ៍កម្មហើយទេ?

វ៉ន: ចាស ។

សុវណ្ណ: ចឹងកាលយើងចាយលុយខ្មែរដំបូងយ៉ាងម៉េចទៅមីង?

វ៉ន: ខ្ញុំវគ្គ ចាយលុយខ្មែរ ធ្លាប់នៅនោះយើងហៅលុយបាតចឹង២០០បាតដល់មកដល់លុយខ្មែរពីរម៉ឺន ចឹងដល់ចឹងទៅវគ្គ ទំរាំបានចេះចាយរលំប្រទ្បំ ។

សុវណ្ណ: ប្រទ្បំយ៉ាងម៉េចមីង?

វ៉ន: ប្រទ្បំ មួយប្រើមួយម៉ឺនចឹងទៅខាងលុយថៃមួយរយចឹងទៅ ខ្ញុំលក់គោមួយដំបូង កាលផ្តាច់ខ្លួនហ្នឹង កាល៩៨ហ្នឹង យកលុយមករាប់វាប្រទ្បំ ។

សុវណ្ណ: ចឹងស្មានថា ម៉ឺនៗលុយបាត?

វ៉ន: ចាស!ម៉ឺនៗឃើញច្រើន ។

សុវណ្ណ: យើងនៅជំរំអូរគ្រាវហ្នឹងយើងមានរបបបើកដូចធម្មតាឬមួយយ៉ាងម៉េច?

វ៉ន: បើកធម្មតា ។

សុវណ្ណ: តែរបបខាងនេះខាងណាអ្នកជួយពេលហ្នឹង?

វ៉ន: គេថាបារាំងជួយៗមិនដឹងជាខាងណាទៀត ខ្ញុំមិនដឹងដែរ ។

សុវណ្ណ: ដឹងថា ខាងបារាំង?

វ៉ន: ចាស ។

សុវណ្ណ: គេចូលមកគេជួយអីខ្លះនៅក្នុងភូមិ នៅក្នុងជំរំហ្នឹង កាលហ្នឹង?

វ៉ន: កាលហ្នឹងគេជួយក្មេងតូចៗចេះមានរបបវា មានរបបកូនក្មេងមានពងទា មានម្សៅមានអីសម្រាប់កូនក្មេងហូបចឹង យើងមនុស្សចាស់មានកំសៀវ មានម៉ុង មានកន្ទេល ចែកអង្ករមានគ្រប់មុន ។

សុវណ្ណ: ចឹងគេមានមកបង្រៀនអីដល់ក្មេងៗខ្លះទេ ឬភូមិគេមានបង្រៀនអីខ្លះទេ កាលនៅអូរគ្រាវហ្នឹង?

វ៉ន: ចាស!គេមានបើកសាលាដែលកាលនៅជំរំហ្នឹង មានគ្រូគេបើកបង្ហាត់កូនក្មេងជាអក្សរខ្មែរអីបានខ្លះ ។

សុវណ្ណ: ចឹងគេមានរើសអ្នកចង់ទៅនៅប្រទេសអីបីអីគេ កាលហ្នឹង?

វ៉ន: កាលជំនាន់ខ្ញុំទៅហ្នឹងវាផុតអស់ហើយ គេរត់ទៅនៅតាំងពីឆ្នាំ៧៩នោះ ។

សុវណ្ណ: មីងចេញពីអូរគ្រាវមីងនៅខាងណាទៀត?

វ៉ន:	ខ្ញុំចុះមកខាងអន្លង់វែង ។

សុវណ្ណ:	ចឹងកាលហ្នឹងទៅនៅអូរត្រាវបានយូរដែល?

វ៉ន:	ចាស ។

សុវណ្ណ:	ទៅនៅបានប្រហែលជាប៉ុន្មានទៅយូរហ្នឹង?

វ៉ន:	នៅបានយូរដែលប្រហែលជាប៉ុន្មានឆ្នាំទេខ្ញុំ ខ្ញុំភ្លេចមិនបានគិតទេ ។

សុវណ្ណ:	ចឹងយើងចុះមកអន្លង់វែងនៅឆ្នាំណា ចុះមកនៅជំបូងណាស់?

វ៉ន:	ចុះមកនៅឆ្នាំ១៩៩១ ។

សុវណ្ណ:	ចុះមកនៅអន្លង់វែង ចុះមកនៅម្តុំណា?

វ៉ន:	ខ្ញុំនៅខាងត្រពាំងប្រិយ ។

សុវណ្ណ:	ចឹងចុះមកខាងត្រពាំងប្រិយ៍?

វ៉ន:	ចាស ។

សុវណ្ណ:	ចឹងចុះមកនៅខាងអន្លង់វែងហ្នឹង យ៉ាងម៉េចដែលពេលចុះមកនៅហ្នឹង?

វ៉ន:	ខ្ញុំនៅបានយូរឆ្នាំចឹងទៅ យួនវាយវៀតណាមវាយទៀតខ្ញុំរត់ទៅខាងទំនប់ដាច់ នៅទំនប់ដាច់ហ្នឹងបានប្រហែលមួយឆ្នាំ ធ្វើស្រែបានតែម្តងយួនវាយទំនប់ដាច់ហ្នឹងទៀតហើយ រត់ទៅខាងជុបរុន ចេញពីជុបរុនមកបានខ្ញុំមកនៅហ្នឹង នៅភូមិចាស់ហ្នឹង ។

សុវណ្ណ:	ចឹងកាលនៅត្រពាំងប្រិយ៍ហ្នឹង នៅក្នុងពេលហ្នឹងយើងមានបិតចំរូងឲ្យទៅខាងកងទ័ពដែលទេកាលហ្នឹង?

វ៉ន:	អត់មានទេ ។

សុវណ្ណ:	ចឹងយើងមានជួយអីខ្លះដល់ខាងទ័ពទេ ដូចជាបិតចំរូងអី?

វ៉ន:	អត់មានទេ បើមកនៅនេះបានធ្វើ នៅត្រពាំងប្រិយ៍មួយសារនោះគិតថាស្រួលហើយអត់មានប្រុងប្រយ័ត្នអីទៀត ។

សុវណ្ណ:	ចឹងកាលហ្នឹងយ៉ាងម៉េចបានគេហៅត្រពាំងប្រិយ៍មីង?

វ៉ន:	ត្រពាំងហ្នឹងមានព្រៃធំវែង ហើយមានព្រៃដុះច្រើន គេដាក់ហៅត្រពាំងប្រិយ៍ចឹងទៅ ។

សុវណ្ណ:	វានៅជិតភ្នំដែរ ត្រពាំងប្រិយ៍ហ្នឹង?

វ៉ន:	អត់ទេ នៅឆ្ងាយ នៅជិតស្រះឈូក ។

សុវណ្ណ:	ចឹងត្រពាំងប្រិយ៍នៅជិតស្រះឈូកទេ?

វ៉ន:	ចាស ។

សុវណ្ណ:	ហើយចេញពីត្រពាំងប្រិយ៍យើងមកនៅខាងណា?

រ៉ន: ខ្ញុំមកនៅខាងទំនប់ដាច់ ។

សុវណ្ណៈ កាលហ្នឹងនៅត្រពាំងប្រិយ៍បានប៉ុន្មានឆ្នាំ?

រ៉ន: ត្រពាំងប្រិយបានយូរដែរ ។

សុវណ្ណៈ កាលមកទំនប់ដាច់មកឆ្នាំណា?

រ៉ន: មកទំនប់ដាច់ឆ្នាំ៩៣ចេះ ៩៣ឬ៩២ទេ ខ្ញុំមកធ្វើស្រែ ។

សុវណ្ណៈ កាលហ្នឹងមានអ៊ុនតាក់ចូលហើយនៅ?

រ៉ន: អ៊ុនតាក់ចូលហើយ ។

សុវណ្ណៈ អ៊ុនតាក់ចូលហើយមកនៅខាងទំនប់ដាច់នេះ?

រ៉ន: ចាស ។

សុវណ្ណៈ អ៊ុនតាក់ចូលខ្ទង់ឆ្នាំ៩២-៩៣មីង?

រ៉ន: ចាស!មកនៅចូលហើយ អ៊ុនតាក់ចូលហើយ ។

សុវណ្ណៈ ចឹងមកនៅនេះឆ្នាំណា ខាងទំនប់ដាច់ហ្នឹង?

រ៉ន: ទំនប់ដាច់ហ្នឹងខ្ញុំនៅឆ្នាំ៩៤ចឹងឯង ។

សុវណ្ណៈ មានមូលហេតុអីបានជាមកទំនប់ដាច់?

រ៉ន: កាលហ្នឹងយួនវាយនៅខាងអន្លង់វែង ពួកខាងវៀតណាមវាយហ្នឹង ខ្ញុំគេចទៅនៅខាងទំនប់ដាច់ ។

សុវណ្ណៈ កាលហ្នឹងខាងរដ្ឋាភិបាលទេ ព្រោះថាយួនគេដកចេញអស់ហើយ?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងប្រទាញប្រទង់គ្នាជាមួយខាងរដ្ឋាភិបាល?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលអ៊ុនតាក់ចូលមកខាងអន្លង់វែង ដើម្បីចរចារជាមួយខាងរដ្ឋាភិបាល គេមានជួយអីខ្លះដល់អ្នកភូមិនៅនេះ?

រ៉ន: ខាងខ្ញុំអត់មានទេ ។

សុវណ្ណៈ ចឹងកាលហ្នឹងខាងអ៊ុនតាក់ចូលមកចឹង មីងមានអារម្មណ៍យ៉ាងម៉េចទៅកាលហ្នឹង ពេលគេមកធ្វើខាងអន្លង់វែងអតីតនៅនេះ?

រ៉ន: កាលហ្នឹងមានអារម្មណ៍ថាអរ ក្រែងវាបានចប់សង្គ្រាមឆាប់ៗ ដល់ទៅមានចប់អី ។

សុវណ្ណៈ ចឹងអ៊ុនតាក់ចេញទៅវិញឆ្នាំណា?

រ៉ន: ខ្ញុំមិនបានដឹងដែរ ។

សុវណ្ណៈ យើងមកទំនប់ដាច់ហើយ?

វ៉នៈ ចាស ។

សុវណ្ណៈ មកទំនប់ដាច់ កាលហ្នឹងយើងមកខាងណា យើងមកនៅខាងណាទំនប់ដាច់?

វ៉នៈ ខាងខ្មែរក្រហម ។

សុវណ្ណៈ តែនៅខាងភូមិណាភូមិ៨៥ភូមិ៨១អី?

វ៉នៈ ខ្ញុំនៅជិត៨១ហ្នឹង ។

សុវណ្ណៈ មកនៅភូមិ៨១ទេ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងយ៉ាងម៉េចបានយើងដឹងថា មានភូមិ៨១?

វ៉នៈ កងទ័ពគេហៅកងពល៨១ចឹងតែម្តង គេហៅ៨១ ។

សុវណ្ណៈ មិនមែនកងពល៨០១?

វ៉នៈ ៨០១នៅនេះ ហើយ៨០២នៅនេះ នៅហ្នឹងគេហៅ៨១ចឹងតែម្តង ។

សុវណ្ណៈ ភូមិ៨១?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងភូមិ៨១គេដាក់ឈ្មោះ តាមទ័ពទេ?

វ៉នៈ គេដាក់តាមទ័ព ព្រោះខ្ញុំទៅចំណុះគេដែរ ។

សុវណ្ណៈ ចឹងពេលណាយើងមកនៅខាងអូរស្មាយនេះវិញ ចឹងចេញពីទំនប់ដាច់ទៅណាទៀត?

វ៉នៈ ចេញពីទំនប់ដាច់មកនេះបណ្តោយ ។

សុវណ្ណៈ មកខាងអូរស្មាយនេះ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងទៅទំនប់ដាច់អស់រយៈពេលប៉ុន្មានដែរ?

វ៉នៈ រយៈពេលមួយឆ្នាំ ។

សុវណ្ណៈ ចឹងរយៈពេលមួយឆ្នាំយើងមកខាងណាវិញ?

វ៉នៈ មកខាងអូរស្មាយ ។

សុវណ្ណៈ ចឹងម៉េចបានជាមកនៅខាងអូរស្មាយ?

វ៉នៈ កាលហ្នឹង មានវាយនៅខាងទំនប់ដាច់ទៀត ខាងរដ្ឋាភិបាលវាយ ។

សុវណ្ណៈ ចឹងខាងរដ្ឋាភិបាលវាយ?

វ៉នៈ ចាស!កងទ័ពខាងរដ្ឋាភិបាលវាយ ។

សុវណ្ណៈ គេវាយដេញពីត្រាំប៉ាំងមក?

វ៉ន់ៈ ចាស ។

សុវណ្ណៈ ពីត្រាំប៉ាំងយើងរត់មកនៅខាងអូរស្វាយមក?

វ៉ន់ៈ ចាស ។

សុវណ្ណៈ កាលហ្នឹងយើងរត់របៀបយ៉ាងម៉េចកាលហ្នឹង?

វ៉ន់ៈ ដើរមក មានរទេះអីចឹងបរដឹកអង្ករអីខ្លះទៅ គ្មានអីជិះទេ ។

សុវណ្ណៈ ចឹងពេលមកនៅអូរស្វាយយើងនៅបានយូរទេ?

វ៉ន់ៈ នៅយូរនៅរហូតដល់ឆ្នាំ៩៨ មកដល់ឥឡូវទៀត ។

សុវណ្ណៈ ចឹងមីងថារត់ឡើងភ្នំម្តងទៀត?

វ៉ន់ៈ អាហ្នឹងនៅមួយភ្លេចទេ គេវាយនៅទំនប់ដាច់ចឹង គេនាំគ្នាឡើងជុបរុនកាសខ្លួនបីបួនប្រាំថ្ងៃ ចឹងចុះមកវិញ មកវិញមកនេះបណ្តោយ ។

សុវណ្ណៈ ចឹងមុនដំបូងនៅទំនប់ដាច់ដល់ពេលគេវាយចូលមកខាងទំនប់ដាច់ហ្នឹងយើងឡើងទៅជុបរុន?

វ៉ន់ៈ ចាស ។

សុវណ្ណៈ ចឹងពេលចុះមកពីជុបរុនមកនៅខាងអូរស្វាយមក?

វ៉ន់ៈ ចាស ។

សុវណ្ណៈ ចឹងមកនៅអូរស្វាយតាំងពី៩៥មក?

វ៉ន់ៈ ចាស ។

សុវណ្ណៈ ចឹងអត់មានផ្លាស់ទៅណាទៀតទេ?

វ៉ន់ៈ អត់ទេ លែងហើយ លែងទៅណាហើយ ។

សុវណ្ណៈ តែគេមានវាយចូលមកដែលអត់?

វ៉ន់ៈ លែងហើយព្រោះមានផ្តាច់ខ្លួនឆ្នាំ៩៨នេះហើយ កាលមួយឆ្នាំនោះក៏លែងមានអីហើយ ។

សុវណ្ណៈ ចឹងកាលខាងខ្មែរក្រហមមានផ្តាច់ខ្លួនចូលជាមួយខាងរដ្ឋាភិបាលបណ្តើរៗគេចាប់ផ្តើមផ្តាច់ខ្លួននោះ ចឹងកាលហ្នឹងខាងអន្លង់វែងគេមានប្រមែប្រមូលប្រជាជនខាងអូរស្វាយនេះឲ្យទៅនៅខាងអន្លង់វែងទេ តាម៉ុក អីមានមកប្រមូលដែលទេ?

វ៉ន់ៈ អត់ទេ ពីណាចង់ទៅណាក៏ទៅៗផ្តាច់ខ្លួនហើយ ខ្លះទៅស្រុកទៅណាអស់ ខ្ញុំនៅតែនេះឯង ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងមានបានដឹងរឿងរ៉ាវគេបែកបាក់ផ្ទៃក្នុងខាងខ្មែរក្រហមមីង ខាងអន្លង់វែងខាងត្រពាំងប្រាសាទ គេបែកបាក់គ្នាអី?

វ៉ន់ៈ ខ្ញុំអត់បានដឹងទេ ។

សុវណ្ណៈ	ចឹងកាលមកនៅអូរស្វាយដំបូងស្រុកភូមិហ្នឹងយ៉ាងម៉េចដែរ?

វ៉នៈ	អត់មានសេុកទេ សុទ្ធតែព្រៃ ព្រៃធំៗទើបកាប់អស់ប្រាំងមិញទេ ទើបវាលទេ កាលពីមុនព្រៃមិនហ៊ានដើរទេ ។

សុវណ្ណៈ	ចឹងសុទ្ធតែព្រៃកាលពីមុនតំបន់នេះមីង?

វ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងគ្រាប់មីនអីមានទេ?

វ៉នៈ	មាន ។

សុវណ្ណៈ	ចឹងដីមីងនៅនេះគឺនៅតាំងពីឆ្នាំ៩៥មកតែម្តង?

វ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងចូលមកដំបូងមីងហ៊ាននៅដែរ ព្រោះសុទ្ធតែជាតំបន់គ្រាប់មីនអីចឹង?

វ៉នៈ	ដឹងថា កន្លែងយើងនេះនៅឆ្ងាយពីបន្ទាយយួន បើមានបន្ទាយបានមាន ។

សុវណ្ណៈ	ចឹងកាលមីងចូលមកមានខ្លាចគ្រាប់មីនអីទេ?

វ៉នៈ	ដំបូងខ្លាចដែរ ដល់ក្តាប់បានថាបន្ទាយវានៅឆ្ងាយចឹងទៅ គេមិនដែលដាក់ទេ គេដាក់តែជិតបន្ទាយ ។

សុវណ្ណៈ	ចឹងមានប្រជាជនអ្នកភូមិជាន់មីនដាច់ដៃជើងមានទេ អ្នកភូមិអីនៅនេះមីង?

វ៉នៈ	អ្នកភូមិនេះអត់មានទេ ។

សុវណ្ណៈ	ចឹងអត់សូវមានបញ្ហាជាមួយគ្រាប់មីនទេ?

វ៉នៈ	ចាស!មិនសូវទេ ។

សុវណ្ណៈ	កាលមីងមកចូលនៅដំបូង មីងមានជួបបញ្ហាអីកើតឡើងខ្លះ?

វ៉នៈ	លំបាកទី១ អត់មានទឹក អត់មានទឹកប្រើទេ ទៅដឹកឆ្ងាយណាស់ ចឹងហូបទឹកអូរ កន្លែងណាជីកចេញៗកន្លែងណាមិនចេញមិនចេញទេ ។

សុវណ្ណៈ	ចឹងមានអីទៀត ក្រៅពីជួបបញ្ហារឿងទឹកអី?

វ៉នៈ	ពិបាកក្នុងការហូបចុក ជាម្ហូបជាបន្លែអីចឹងទៅ ហូបដើរកាត់កូនផ្តៅហូបទេ ដំបូងនោះមកដំបូងអត់ទាន់ដាំអីកើត ។

សុវណ្ណៈ	អីគេ គមផ្តៅ?

វ៉នៈ	ចាស!ចុងផ្តៅ គមអន្សែអីចឹងទៅ ហូបចឹងៗឯង ដល់មកនៅយូរៗមានអូរមានអីចឹងកាប់ព្រៃអីដាំបន្លែហូបខ្លួនឯង កាលនោះមានគ្រាប់អីចឹង ខ្លះគេបានមកដាប់ ខ្លះគេទៅផ្ទះប្រជាជន ផ្ទះម៉ែឪគេបានមកចេះតែចែកគ្នាដាំទៅ ។

សុវណ្ណៈ គ្រាប់អីគេមីង?

រ៉ន: គ្រាប់ស្តែគ្រាប់អីចឹង រហូតដល់ខាងអន្ទង់វែងហ្នឹងគេមានបើកលក់ យើងទៅទិញមក យកមកដាំបានហូបរហូត ។

សុវណ្ណៈ ចឹងមីងសព្វថ្ងៃនេះ មីងមានពេញចិត្តការរស់នៅបច្ចុប្បន្ននេះទេ?

រ៉ន: ចាស!ពេញចិត្ត ។

សុវណ្ណៈ មានមូលហេតុអីបានជាមីងពេញចិត្ត?

រ៉ន: មូលហេតុពេញចិត្តយើងធ្វើអីបាន យើងលក់បានលុយ បានអីចាយដោះស្រាយក្នុងជីវភាពចឹងទៅ វាមិនដូចមុន មុនយើងលក់មិនបាន គ្មានអីផ្សារចឹង យើងខ្វះខាត ចឹងរាល់ថ្ងៃនៅខ្វះតែកន្លែងផ្សារមួយទេ យើងមានផ្សារធ្វើអីត្រូវលក់បានគឺស្រួលមែនទែនតែម្តង ត្រូវមានផ្លូវអីចេះទៀត អត់មានពិបាកទេ ព្រោះខ្ញុំលំបាកឆ្អែតហើយនៅកន្លែងនេះ កាលពីមិនមិនមានផ្លូវចេះទេ មានតែផ្លូវរទេះ ទៅត្រឹមអន្ទង់វែងអីដេកផ្លូវមួយយប់បានៗ ។

សុវណ្ណៈ កាលមុនផ្លូវយ៉ាងម៉េច?

រ៉ន: ផ្លូវពិបាក ផ្លូវបររទេះ ហើយនឹកស្មានថាមិនបានប៉ុននេះផង ។

សុវណ្ណៈ ចឹងមានចំណុចណាដែលមីងមិនចូលចិត្តឬក៏មិនពេញចិត្ត កាលរស់នៅពេលបច្ចុប្បន្ននេះ មីងមានទេ ដែលមីងមើលឃើញខុសប្លែកពីមុន?

រ៉ន: អត់ទេ ។

សុវណ្ណៈ ចឹងអត់មានចំណុចណាដេលមីងមិនពេញចិត្តទេ?

រ៉ន: ចាស!ឲ្យតែបានប៉ុណ្ណឹងទៅ ។

សុវណ្ណៈ ចឹងចំពោះដីធ្លីរបស់មីងមានជួបបញ្ហាអីទេ ជាប់ដីរបស់របស់ក្រុមហ៊ុនមានទេមីង?

រ៉ន: ខាងខ្ញុំអត់មានទេ ដីខ្ញុំមានតែមួយដុំហ្នឹងឯង ។

សុវណ្ណៈ ចឹងអត់មានជាប់បញ្ហាជាមួយក្រុមហ៊ុនអីទេ?

រ៉ន: ចាស!អត់មានទេ ។

សុវណ្ណៈ ចឹងសម្រាប់ មីងដែលធ្លាប់ឆ្លងកាត់ពីរបបមួយទៅរបបមួយតាំងពី លន់ នល់ តាំងពីខ្មែរក្រហម តាំងពីមកតស៊ូនៅនេះ រហូតមកដល់បច្ចុប្បន្ននេះ ចឹងរបបណាមួយដែលមីងពេញចិត្តជាងគេមីង?

រ៉ន: របបសព្វថ្ងៃរបបចាយលុយនេះឯង វាមានជីវភាពធូរធារមិនដូចជាសម័យយើងហៅថាខ្មែរក្រហម មិនស្គាល់លុយកាក់ ។

សុវណ្ណៈ សម្រាប់ខ្លួនមីងផ្ទាល់ មីងយល់ឃើញថា សង្គ្រាមវាបានផ្តល់ប្រយោជន៍ដល់ប្រជាជនឬមួយមិនបានផ្តល់ទេ?

វ៉ន: មិនផ្តល់ទេ សង្គ្រាមមានតែហិនហោច ។

សុវណ្ណៈ ហិចហោចយ៉ាងម៉េចទៅមីង?

វ៉ន: ហិនហោចទី១មនុស្សស្លាប់ទី២មិនបានធ្វើអីសោះប្រជាជនត្រៀមរត់រហូត អត់មានរីកចំរើនទៅណាកើតទេ ។

សុវណ្ណៈ ចឹងរាល់ថ្ងៃនេះមីងទាក់ទងជាមួយអ្នកជិតខាងយ៉ាងម៉េចដែលមីង ច្រើននិយាយអីគេខ្លះជាមួយអ្នកជិតខាង?

វ៉ន: អត់មានរឿងអីទេ និយាយតែរឿងរកស៊ីដាំនេះដាំនោះ ។

សុវណ្ណៈ ចឹងយើងនិយាមមានការភ័យខ្លាចឬយើងសប្បាយចិត្ត?

វ៉ន: អត់មានភ័យទេ ដូចជាសព្វថ្ងៃលែងភ័យអីហើយ ។

សុវណ្ណៈ ចឹងយើងពិភាក្សាគ្នាមិនមានការភ័យខ្លាចទេ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលពីមុន កាលមីងធ្វើការនៅការដ្ឋានស្រែអំបិល មីងមានដែលពិភាក្សាគ្នាជាមួយក្រុមធ្វើការងារជាមួយគ្នាទេមីង កាលហ្នឹងដើរនិយាយលេង ពិភាក្សារឿងនេះរឿងនោះកាលមីងនៅក្នុងរបបបីឆ្នាំជាមួយខ្មែរក្រហម?

វ៉ន: ចាស!អត់ទេ និយាយបានរឿងធ្វើការទេ ។

សុវណ្ណៈ ចឹងក្រៅពីរឿងធ្វើការយើងមិនអាចនិយាយគ្នាបានទេ?

វ៉ន: ចាស!ហើយក៏មិនអាចដឹងរឿងអីទៀត ។

សុវណ្ណៈ តែយើងមានដែលពិភាក្សានិយាយលេងសើចជាមួយគ្នាបានទេ?

វ៉ន: យើងនិយាយលេងសើចធម្មតាបាន តែនិយាយរឿងការងារ រឿងផ្ទៃក្នុងរឿងនយោបាយអីយើងមិនដឹងទេ ។

សុវណ្ណៈ តែការបិភាក្សាគ្នាយើងនិយាយទាំងសប្បាយចិត្តឬមិនសប្បាយចិត្តទេ ពេលហ្នឹងមីង?

វ៉ន: មិនសប្បាយចិត្តទេ ព្រោះបែកម៉ែឪមិនដែលបានជួបរាប់ឆ្នាំ ម្នាក់ៗនឹកដូចគ្នា ។

សុវណ្ណៈ ចឹងមីងនៅ លេងផ្ទះដំបូងទៅលេងឆ្នាំណា ទៅលេងបងប្អូន?

វ៉ន: កាលខ្ញុំផ្តាច់ខ្លួនហើយឆ្នាំ៩៨ហើយ ។

សុវណ្ណៈ ចឹង៩៨ផ្តាច់ខ្លួនហើយមីងបានទៅលេងស្រុកកំណើតវិញ?

វ៉ន: ចាស ។

សុវណ្ណៈ	កាលមីងទៅដល់ដំបូងអ្នកផ្ទះមីងស្គាល់ដែរ?

វ៉នៈ	ស្គាល់តែគាត់អត់មានសង្ឃឹមដែលហ្នឹង ។

សុវណ្ណៈ	ម៉េចបានជាគេស្គាល់ ព្រោះមីងចេញមកពីផ្ទះតាំងពីនៅក្មេង ហើយមីងទៅវិញធំរាងចំណាស់ដែលហើយ ចឹងម៉េចបានជាអ្នកផ្ទះស្គាល់?

វ៉នៈ	ស្គាល់ អត់អីទេ វាបាត់តែឈ្មោះ ។

សុវណ្ណៈ	គេនៅស្គាល់រូបរាងយើង?

វ៉នៈ	ចាស ។

សុវណ្ណៈ	ខ្ញុំគិតថា រូបរាងមីងប្លែក ពេលឆ្នាំ៧៥ហ្នឹង មីងអាយុទើប១០ជាងអីហ្នឹង ដល់ពេលទៅលេងឆ្នាំ៩៨មីងខ្ទង់៤០ហើយ ចឹងរូបរាងយើងវាខុសពីមុនឆ្ងាយ ចឹងពេលទៅដល់ភ្លាមគេស្គាល់យើងភ្លាមឬមួយយើងណែនាំខ្លួនឲ្យគេស្គាល់សិន?

វ៉នៈ	បើបងប្អូនយើងបង្កើតនេះយើងនៅស្គាល់គ្នាបាន បើអ្នកភូមិហ្នឹងតែម្ដងគេប្លែកច្រើនដែរ ខ្លះក៏ស្គាល់ខ្លះសួរទៅបានដឹង ។

សុវណ្ណៈ	ចឹងជួបគ្នាដំបូងមានអារម្មណ៍យ៉ាងម៉េច ពេលយើងជួបបងប្អូន?

វ៉នៈ	មានអារម្មណ៍ រំភើបសប្បាយណាស់ នឹកមិនស្មានដល់ថាបានទៅស្រុកវិញទេ បើតែសង្គ្រាមដូចមុនមិនបានទៅស្រុកទេខ្ញុំ កុំផ្ដាច់ខ្លួនទាន់បានទៅស្រុក ។

សុវណ្ណៈ	ចឹងទៅដំបូងគេគិតថាយើងយ៉ាងម៉េចមីង?

វ៉នៈ	គេគិតថា មិនបានជួបយើងទៀតទេ ស្មានថាយើងនៅក្នុងព្រៃ ។

សុវណ្ណៈ	មួយឆ្នាំមីងបានទៅលេងស្រុកប៉ុន្មានដងដែរ?

វ៉នៈ	ឆ្នាំនេះខ្ញុំបានទៅពីរដងហើយ ព្រោះឪពុកគាត់ឈឺមួយសារ ខ្ញុំទៅមួយសារមុនភ្ជុំ ឥឡូវគាត់ខូច កាលគាត់ឈឺធ្ងន់ខ្ញុំទៅមួយសារទៀត ។

សុវណ្ណៈ	ចឹងមានន័យមួយឆ្នាំមីងបានទៅលេងស្រុកពីរដង?

វ៉នៈ	ចាស!ម្ដងយ៉ាងតិច ។

សុវណ្ណៈ	មីងច្រើនទៅក្នុងពេលណា?

វ៉នៈ	ខ្ញុំទៅខែ៥ចឹងឯង ។

សុវណ្ណៈ	ទៅពេលចូលឆ្នាំ ពេលភ្ជុំ?

វ៉នៈ	ពេលភ្ជុំហើយ ។

សុវណ្ណៈ	ចឹងអ៊ីដែលយើងឧស្សាហ៍ទៅច្រើនជាងគេ ទៅពេលភ្ជុំពេលចូលឆ្នាំឬយ៉ាងម៉េចមីង?

វ៉នៈ	ខ្ញុំមិនដែលបានទៅទេ ពេលចូលឆ្នាំ ទៅតែពេលច្រូតហើយទំនេរបានទៅ ។

សុវណ្ណៈ	ចឹងបងប្អូនមានដែលមកលេងយើងនៅនេះវិញទេ?

វ៉នៈ	ដែរ ។

សុវណ្ណៈ	គេមកលេងប៉ុន្មានដងហើយ បើមីងគិតមើលទៅ?

វ៉នៈ	ខ្លះមកតែម្ដងខ្លះមកពីរដង បងខ្ញុំបង្កើតមកពីរដង គាត់មកការក្មួយ កាលខ្ញុំការកូនគាត់មក ដែរ ។

សុវណ្ណៈ	ចឹងមីងយ៉ាងម៉េចបានជាមិនរើផ្ទះទៅនៅស្រុកកំណើតវិញ?

វ៉នៈ	បើខ្ញុំទៅស្រុកអត់មានដីទេ ដីគេដកអស់ ដីខ្ញុំច្រើន កាលនៅក្មេងធ្វើស្រែឡើងខ្ជិលដីច្រើន ឥឡូវទៅដល់គេចែករបបគ្នាអស់ ចឹងខ្ញុំមានរបបដីអត់មាន មិនថារកស៊ីអីទៀតខ្ញុំទៅដល់ស្រុកនោះ ហើយនៅនេះមានដីបន្តិចបន្តួចធ្វើស្រែ ។

សុវណ្ណៈ	ចឹងរាល់ថ្ងៃមីងកាន់សាសនាអីគេ?

វ៉នៈ	ខ្ញុំសាសនាព្រះពុទ្ធ ។

សុវណ្ណៈ	ពេលទៅវត្តមីងច្រើនធ្វើបុណ្យឧទ្ទិសកុសល្យទៅខាងណាមីង?

វ៉នៈ	ឧទ្ទិសកុសល្យជូនដល់ម៉ែឪ ជីដូនជីតាយើងទៅ ។

សុវណ្ណៈ	ចឹងចេះកាលហ្នឹងមីងខានធ្វើបុណ្យទានហ្នឹងយូរមកហើយ បើយើងបកទៅក្រោយវិញតាំងពី ៧៥ រហូតដល់មីងឆ្នាំ៩៨នេះ យើងអត់មានទៅវត្តទៅវ៉ាហ្នឹងគេទេ ចឹងពេលដែលទៅវត្តហ្នឹងមីងគិតថាទៅក៏បានមិនទៅក៏បាន មីងមានដែលគិតចឹងទេ?

វ៉នៈ	ចិត្តតែទៅមានបុណ្យទានអីមិនដែលខានទេ ។

សុវណ្ណៈ	ព្រោះយើងខានគោរពសាសនាវាយូរមកហើយ?

វ៉នៈ	ចាស ។

សុវណ្ណៈ	ចឹងវត្តហ្នឹងយើងគិតថា ទៅក៏បានមិនទៅក៏បានដែរ វត្តមិនមានសំខាន់អីទេ មីងមានគិតចឹងទេ កាលធ្វើបុណ្យទានហ្នឹង?

វ៉នៈ	អត់ទេ ចង់ធ្វើបុណ្យទាន ព្រោះចាស់ៗហើយចង់ធ្វើបុណ្យ ។

សុវណ្ណៈ	មីងយល់ឃើញយ៉ាងម៉េចដែលបានជាទៅវត្ត?

វ៉នៈ	យើងកាន់សាសនាអី យើងជឿលើសាសនានោះ កាន់ខាងព្រះពុទ្ធជឿខាងព្រះពុទ្ធ ។

សុវណ្ណៈ	ចឹងកាលនៅតស៊ូយើងមានទៅវត្តអីខ្លះទេ កាលហ្នឹង?

វ៉នៈ	កាលហ្នឹងអត់មានទេ អត់មានវត្តទេ អត់មានលោកសង្ឃទេ ។

សុវណ្ណៈ	ចឹងពេលភ្ជុំពេលចូលឆ្នាំយើងម៉េច មីង?

វ៉ន: ពេលភ្ជុំនាំគ្នាវិចនំហូបចឹងទៅ ហើយសែន វិចនំហើយស្ងោឆ្អិន ស្ងឆ្អិន ល្ងាចឡើងនាំគ្នាសែនទៅ ផ្ទះខ្ញុំក៏សែនចឹងទៅ ។

សុវណ្ណ: តែយើងអត់មានយកទៅវត្តទេ?

វ៉ន: អត់ទេ ។

សុវណ្ណ: ចឹងឧទាហរណ៍ថា មានពិធីអ្វីមួយ ដូចជារៀបការ យើងមានអញ្ជើញភ្ញៀវមកចូលរួមមាន មានលក្ខណៈត្រឹមត្រូវមានគុ គោរពសាសនាដូចយើងឥឡូវទេ?

វ៉ន: អត់ទេ កាលនោះមិនមានទេ គ្មានលោកផង ។

សុវណ្ណ: ចឹងយើងធ្វើយ៉ាងម៉េចទៅ ពេលយើងចង់គោរពប្រត្តិបត្តិសាសនាអី?

វ៉ន: មានតែដុតធូបហើយរំលឹកតែប៉ុណ្ណឹងឯង មានតែសែនរំលឹក ។

សុវណ្ណ: ចឹងយើងមានអញ្ជើញចាស់ៗមករៀបចំពិធីអីទៅ?

វ៉ន: ចាស!អត់មានលោកទេ កាលហ្នឹង ។

សុវណ្ណ: ចឹងមីងរាល់ថ្ងៃគេមានដាក់សៀវភៅទាក់ទងនិងរឿងខ្មែរក្រហមឲ្យក្មេងរៀនតាមសាលាណា មីង ដើម្បីក្មេងៗជំនាន់ក្រោយរៀនសូត្រដឹងពីរបបខ្មែរក្រហម គេមានបង្រៀននៅតាមសាលារៀន តើមីងគិតថា ក្មេងៗជំនាន់ក្រោយគួរតែរៀនសូត្របុមិនគួររៀនសូត្រឲ្យដឹងពុ ពីរបបខ្មែរក្រហមទេ?

វ៉ន: បើតាមខាងសាលាគេអប់រំចឹងវាត្រូវហើយ ព្រោះគេមិនឲ្យក្មេងៗធ្វើត្រាប់តាមចឹងទៅ ។

សុវណ្ណ: ចឹងរៀនឲ្យដឹងពុដើម្បីកុំឲ្យយកត្រាប់តាមមីង?

វ៉ន: ចាស ។

សុវណ្ណ: ចឹងមីងគិតថារៀនសូត្រពីរបបខ្មែរក្រហមហ្នឹងវាសំខាន់ទេមីង ការយើងរៀនសូត្រឲ្យបាន ដឹងពុពីសម័យខ្មែរក្រហមហ្នឹង សំខាន់បុមិនសំខាន់?

វ៉ន: សំខាន់ដើម្បីក្មេងឲ្យវាយល់ដឹងពីការតស៊ូរបស់ម៉ែឪពីមុន ។

សុវណ្ណ: មានអីទៀតទេ.?

វ៉ន: មានតែប៉ុណ្ណឹង ។

សុវណ្ណ: មីងសម្រាប់មីងមកនៅតស៊ូនេះ ខ្លួនឯងផ្ទាល់គិតថានៅពេលបច្ចុប្បន្នមានសល់អីខ្លះដែលមីង ដែលចេញពីការតស៊ូយើង មករស់នៅតំបន់តស៊ូនេះណា?

វ៉ន: អត់មានអីសោះ ។

សុវណ្ណ: មីងម៉េច គិតថាអត់មានអីសោះ?

វ៉ន: របបពីមុនមកខ្ញុំមិនមានបានអីទេ ខ្ញុំប្រជាជនធម្មតាមានអី អត់មានរកស៊ីអីបានផង កាលរបបនោះ ស៊ីរបបអង្ករក៏របបម្ហូបក៏របប គេអត់មានឲ្យរកស៊ីអី ។

សុវណ្ណៈ ចឹងការរស់នៅបែបហ្នឹង មឹងពេលចិត្តទេ?

វ៉ន: អត់ទេ ។

សុវណ្ណៈ ការរស់នៅយើងចាំបើករបបពីគេ មឹងពេញចិត្តទេ?

វ៉ន: ខ្ញុំអត់មានពេញចិត្តទេ ។

សុវណ្ណៈ មានមូលហេតុអីមឹងមិនពេញចិត្ត?

វ៉ន: ព្រោះតម្រូវការរបស់យើងវាមិនគ្រប់គ្រាន់ យើងចង់បាននេះទៅអត់ចង់បាននោះទៅអត់ គេឲ្យរបបផ្សេងយើងមិនពេញចិត្ត ។

សុវណ្ណៈ ចឹងមឹងមានអីចង់សួរខ្ញុំខ្លះទេ ខ្ញុំដូចជាសួរមឹងច្រើនហើយ មានអីចង់សួរទេ?

វ៉ន: ខ្ញុំអត់មានអីចង់សួរទេ ។

សុវណ្ណៈ ចឹងខ្ញុំអរគុណមឹងច្រើន ដែលបានផ្តល់បទសម្ភាសឲ្យខាងខ្ញុំមឹងណា ។

វ៉ន: ចាស ។

សុវណ្ណៈ ចឹងអរគុណ ។

វ៉ន: ចាស ។

**ចប់**